ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

# State Budget of Kingdom of Cambodia



ខែ សីហា ឆ្នាំ ២០១១

# ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

# ថវការដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

# STATE BUDGET OF KINGDOM OF CAMBODIA

**ដឹកនាំ និង កែសម្រួលដោយ :**

**ឯកឧត្តម អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា

**ឯកឧត្តម ប៊ុន ឃុន្ធា** អគ្គនាយកសេវាច្បាប់ និង
សម្ពហភាពដែនដី

លោក **តាំង សុចិត្រា** ប្រធាននាយកដ្ឋានស្រាវជ្រាវទូទៅ

**សិក្សាស្រាវជ្រាវ និង ចងក្រងដោយ**
**ការិយាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លោក **ម៉ែន ខែមវិបុ** ប្រធានការិយាល័យ

លោក **ចំរើន ថាវុធ** អនុប្រធានការិយាល័យ

# អារម្ភកថា

ចាប់តាំងពីឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្នប្រជាជនកម្ពុជាបានប្ដេជ្ញាកសាងប្រទេសជាតិខ្លួនឲ្យទៅជា "កោះសន្តិភាព" ឡើងវិញផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ការធានាសិទ្ធិមនុស្ស ការគោរពច្បាប់ ការទទួលខុសត្រូវខ្ពស់ ព្រមទាំងការរីកចំរើនលូតលាស់សម្បូររុងរឿងជានិច្ចនិរន្ដ ស្ថិតក្រោមស្មារតីវឌ្ឍមនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងដំណើរឆ្ពោះទៅនេះគឺជាផ្លូវមួយដ៏វែង និងលំបាកបំផុតដោយសារស្ទើរគ្រប់វិស័យនៃខឿនអភិវឌ្ឍន៍ប្រទេសជាតិត្រូវបានបំផ្លាញ ដោយសារសង្គ្រាមរ៉ាំរ៉ៃអស់ជាង២ទសវត្សកន្លងមក។ ជាលទ្ធផលនៃសង្គ្រាម គឺបានបន្សល់ទុកឲ្យយើងនូវអនាថាជនស្ត្រីមេម៉ាយ និងក្មេងកំព្រាជាច្រើន ដែលតម្រូវឲ្យរាជរដ្ឋាភិបាលបច្ចុប្បន្នត្រូវរ៉ាប់រងដោះស្រាយ ។ ក្នុងនាមជាប្រទេសក្រីក្រមួយក្នុងចំណោម ប្រទេសក្រីក្រដ៏ទៃទៀតលើពិភពលោកយើងត្រូវការធនធានជាច្រើនដើម្បីស្ដារ និងអភិវឌ្ឍប្រទេសជាតិ។ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានខិតខំពង្រឹងខឿនសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់លើសរសៃឈាម នៃខ្សែសង្វាក់វិនិយោគដូចជា ការស្ដារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងថាមវ័ន្ត ធ្វើការកែលំអសោភ័ណភាពប្រទេស ដើម្បីជំរុញវិស័យទេសចរណ៍ដោយបានខិតខំគៀរគរវិនិយោគិនបរទេសមកចូលរួមវិនិយោគក្នុងប្រទេសកម្ពុជា ។

ក្នុងនោះព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ក៏បានខិតខំចូលរួមចំណែកក្នុងការងារជំរុញ ការវិនិយោគនេះផងដែរ ដោយបានខំប្រឹងប្រែងពង្រឹងនីតិរដ្ឋ តាមរយៈបង្កើតច្បាប់ថ្មីៗជំរុញការអនុវត្តច្បាប់ ការពង្រឹងប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌លើគ្រប់វិស័យ។ ព្រឹទ្ធសភាបានខិតខំពង្រឹងតួនាទីរបស់ខ្លួនជាចំបងដើម្បីក្លាយជាកំលាំងចលករមួយ ក្នុងការធានានូវការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការរបស់រដ្ឋ និងការអភិវឌ្ឍឃុំសង្កាត់លើគ្រប់វិស័យ ។ ជាពិសេស បានចូលរួមចំណែកអប់រំប្រជាពលរដ្ឋ គ្រប់ស្រទាប់វណ្ណៈឲ្យយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនក្នុងឋានៈជាម្ចាស់ភាសនាដ៏ពិតប្រាកដនៃប្រទេសជាតិ ។

ចំពោះវិស័យហិរញ្ញវត្ថុ ពិសេសការគ្រប់គ្រងថវិការដ្ឋ ព្រឹទ្ធសភាបានរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេលខ្លី (២០០៨-២០១០) រយៈពេលមធ្យម (២០១០-២០១៣) និងរយៈពេលវែង (២០១៤-២០១៨) ក្នុងការពង្រឹងតួនាទីរៀបចំ និងតាមដានថវិកា ការអភិវឌ្ឍសមត្ថភាពការងារសវនកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ជាតិ។

ដើម្បីពង្រឹងការងារថវិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំសៀវភៅនេះឡើងដោយប្រមូលផ្ដុំនូវ បទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ដើម្បីធ្វើជាឯកសារសិក្សា និងក៏ជាឧបករណ៍ជំនួយសំរាប់អនុវត្តការងារថវិការដ្ឋផងដែរ ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សូមសង្ឃឹមយ៉ាងមុតមាំថាសៀវភៅនេះនឹងរួមចំណែកយ៉ាងសំខាន់ ក្នុងការផ្តល់ព័ត៌មានជូនដល់ សិស្ស និស្សិត មន្ត្រីរាជការថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីដំណើរការរៀបចំថវិកាជាតិ និងការវិវត្តនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពាក់ព័ន្ធនឹងដំណើរការថវិកាឲ្យសម្រេចបានជោគជ័យ និងមានការអភិវឌ្ឍជានិច្ចនិរន្តរ៍ ។

ភ្នំពេញ, ខែសីហា ឆ្នាំ ២០១១

# មាតិកា

ទំព័រ


អារម្ភកថា ..... i

សេចក្តីផ្តើម ..... ០១

ជំពូក ១ ប្រវត្តនៃការរៀបចំថវិការដ្ឋ

(ពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០០៨) ..... ០៣

ផ្នែកទី ១ យន្តការក្នុងការរៀបចំថវិកា

១.ការរៀបចំ និងអនុម័តថវិកា

(ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨) ..... ០៤

១.១ វិធីបរិបថ និងប្រតិទិនថវិកា ..... ០៤

១.២ ធនធាន និងបន្ទុករបស់រដ្ឋ ..... ០៦

១.៣ បទបញ្ញានៃថវិកា ..... ០៨

ផ្នែកទី ២ ប្រវត្តនៃការបង្កើតថវិកាថ្នាក់ក្រោមជាតិ ..... ០៩

២. ដំណាក់កាលចាប់ផ្តើមអនុវត្តថវិកាថ្នាក់ក្រោមជាតិ ..... ១០

២.១ ថវិកាខេត្ត ក្រុង

២.១.១ ការរៀបចំ និងអនុម័តថវិកាខេត្ត ក្រុង ..... ១២

២.១.២ បន្ទុក និងធនធានរបស់ខេត្ត ក្រុង ..... ១២

៣. ដំណើរការច្បាប់ស្តីពី - ការគ្រប់គ្រងរដ្ឋបាល

ឃុំ សង្កាត់ - ឆ្នាំ ២០០១ ..... ១៦

៣.១ អំពីថវិកា ឃុំ សង្កាត់

៣.១.១ ការរៀបចំ និងអនុម័តថវិកា ........................ ១៧

៣.១.២ ការអនុវត្តថវិកា ........................................ ១៩

៣.១.៣ ចំណូល ចំណាយរបស់ឃុំ សង្កាត់ ............... ១៩

**ជំពូក ២ ដំណើរការរៀបចំថវិការដ្ឋ**

(ពីឆ្នាំ ២០០៨ ដល់បច្ចុប្បន្ន) ................................ ២៣

**ផ្នែកទី ១ អំពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ** .................. ២៦

៤. និយមន័យថវិការដ្ឋ .................................................. ២៧

៥. ថវិកាថ្នាក់ជាតិ

៥.១ កាលវិភាគនៃរៀបចំថវិកា ...................................... ២៨

៥.២ ចំណូល ចំណាយថវិការដ្ឋ

៥.២.១ ចំណូលថវិការដ្ឋ .............................................. ៣៣

៥.២.២ ចំណាយថវិការដ្ឋ .............................................. ៣៥

**ផ្នែកទី ២ រដ្ឋបាលថ្នាក់ក្រោមជាតិ**

៦. ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ................................ ៤១

៦.១ ប្រព័ន្ធហិរញ្ញវត្ថុ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ... ៤១

៦.២ ការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ.................... ៤១

៦.៣ កាលបរិច្ឆេទនៃឆ្នាំថវិកា .......................................... ៤១

៦.៤ ការរៀបចំ និងការអនុម័តថវិកា ................................ ៤២

៦.៥ បន្ទុក និងធនធានហិរញ្ញវត្ថុរបស់រដ្ឋបាល
ថ្នាក់ក្រោមជាតិ

៦.៥.១ ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ............ ៤៩
៦.៥.២ ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ............ ៤៩

**ជំពូក ៣ នីតិវិធីក្នុងការសុំសច្ចាប័នពីសភា ............ ៤៩**
៧. កាលវិភាគនៃការសុំសច្ចាប័ន
៧.១ ថវិកាថ្នាក់ក្រោមជាតិ ............ ៤៩
៧.២ ថវិកាថ្នាក់ជាតិ ............ ៥០
៧.៣ ឯកសារភ្ជាប់ ............ ៥០
៨. ការចូលជាធរមាននៃអត្ថបទច្បាប់ហិរញ្ញវត្ថុ ............ ៥១

**ជំពូក ៤ ការអនុវត្តមុខងារសវនកម្ម**
**ផ្នែកទី ១ ការអនុវត្តសវនកម្មលើថវិកា**
៩. គណនេយ្យ និងការត្រួតពិនិត្យថវិកា ............ ៥៣
៩.១ ប្រភេទនៃសវនកម្ម ............ ៥៣
៩.២ ការអនុវត្តមុខងារសវនកម្មជាតិ ............ ៥៥
៩.២.១ អ្វីទៅជាការអនុវត្តសវនកម្មផ្ទៃក្រៅ ............ ៥៥
៩.២.២ ប្រភេទនៃសវនកម្មផ្ទៃក្រៅរបស់
រាជរដ្ឋាភិបាល ............ ៥៦
៩.៣ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់
រាជរដ្ឋាភិបាល ............ ៥៦
៩.៣.១ អ្វីទៅរបាយការណ៍ហិរញ្ញវត្ថុសរុប ? ............ ៥៧
៩.៣.២ ការធ្វើសវនកម្មលើសេចក្តីព្រាងច្បាប់ស្តីពី
ការទូទាត់ថវិការដ្ឋ ............ ៥៧

៩.៤ សវនកម្មផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល
៩.៤.១ គោលការណ៍ទូទៅ ........................................ ៦១
៩.៤.២ គោលបំណងនៃការបង្កើតសវនកម្មផ្ទៃក្នុង ...... ៦២
៩.៤.៣ ការបង្កើតសវនកម្មផ្ទៃក្នុង និងរចនាសម្ព័ន្ធ ...... ៦២
៩.៤.៤ តួនាទី និងភារកិច្ចសវនកម្មផ្ទៃក្នុង ...................... ៦៣
៩.៤.៥ មុខងារ និងការទទួលខុសត្រូវរបស់
សវនកម្មផ្ទៃក្នុង........................................................ ៦៣
៩.៤.៦ បេសកម្មសវនកម្មផ្ទៃក្នុង........................................ ៦៧
៩.៤.៧ ស្តង់ដារសវនកម្មផ្ទៃក្នុង និងក្រមសីលធម៌........ ៦៨
៩.៥ ការធ្វើសវនកម្មលើអាជ្ញាធរសវនកម្មជាតិ................ ៦៨

**ផ្នែកទី ២ អំពីព្រះមហាក្សត្រ**

១០. ការត្រួតពិនិត្យថវិការដ្ឋដោយព្រះមហាក្សត្រ ............ ៦៩

**ឯកសារយោង** ..................................................................... ៧០

**សេចក្តីផ្តើម**

ព្រះរាជាណាចក្រកម្ពុជាបានបង្កើតច្បាប់ស្តីពី " ប្រព័ន្ធហិរញ្ញវត្ថុ " ដំបូងឡើងក្នុងពេលដែលយើងបានស្តារឡើងវិញនូវលិទ្ធិប្រជាធិបតេយ្យ បន្ទាប់ពីយើងបានអនុវត្តតាមលិទ្ធិសង្គមនិយមអស់ជាច្រើនឆ្នាំ ។ ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ។

សេចក្តីត្រូវការនៃច្បាប់ខាងលើត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញដើម្បីកំណត់ក្របខណ្ឌគតិយុត្តនៃនីតិវិធីចំណាយ និងចំណូលសាធារណ:។ដោយសារភារកិច្ចនេះមានសារ:សំខាន់ដែលជាអាយុជីវិតជាតិទើបរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តមុនច្បាប់ដទៃទៀត ។ រហូតមកដល់ឆ្នាំ ១៩៩៦ ដើម្បីអភិវឌ្ឍប្រទេសជាតិបានឆាប់រហ័ស រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តប្រព័ន្ធវិមជ្ឈការ ដោយបានធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ ខេត្ត ក្រុងព្រោះស្ថិតនៅជិតនឹងប្រជាពលរដ្ឋ ។ រាជរដ្ឋាភិបាលបានចេញជាអនុក្រឹត្យលេខ ០៧ អនក្របកចុះថ្ងៃទី៣១ ខែមករា ឆ្នាំ ១៩៩៦ ស្តីពី " ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង " បន្ទាប់មកក៏បានបង្កើតឲ្យទៅជាច្បាប់ពេញលេញ ដែលហៅថាច្បាប់ស្តីពី " របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង " ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ។ ចាប់ពីពេលនោះមកប្រព័ន្ធថវិការដ្ឋចាប់ផ្តើមមានពីរថ្នាក់គឺ ថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រុង។

ជាបន្ថែមទៀតព្រះរាជាណាចក្រកម្ពុជាបានយល់ឃើញអំពីតំលៃនៃទំនាក់ទំនងអន្តរជាតិក្នុងការជួយស្តារ និងកសាងប្រទេសជាតិ ហើយក៏បានធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលក្នុងតំបន់អាស៊ាន និងពិភពលោក ។

គុណវិបត្តិនៃសមាហរណកម្មសេដ្ឋកិច្ចនេះ បានធ្វើឲ្យពន្ធគយថយចុះរហូតដល់សូន្យ ធ្វើឲ្យប៉ះពាល់ដល់ចំណូលថវិការដ្ឋ ។ រាជរដ្ឋាភិបាលបានធ្វើការកែសម្រួលប្រព័ន្ធថវិការដ្ឋដោយបង្កើនចំណូលផ្ទៃក្នុងដើម្បីទប់ទល់ចំណាយ តាមរយៈការអនុវត្តប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការដោយធ្វើការកែសម្រួលច្បាប់ស្តីពី " ប្រព័ន្ធហិរញ្ញវត្ថុ " ឲ្យទៅជាបីថ្នាក់គឺថ្នាក់រាជធានី ខេត្ត ថ្នាក់ ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ដើម្បីធានាបាននូវការអភិវឌ្ឍជនបទឲ្យបានខ្លាំងក្លា និងភាពជៀជាក់លើថវិការដ្ឋសំដៅធានាបាននូវការប្រមូលធនធានហិរញ្ញវត្ថុឲ្យបានល្អប្រសើរ ។

# ជំពូក ១

## ប្រវត្តនៃការរៀបចំថវិការដ្ឋ[១]

### ( ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ ២០០៨ )

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងឲ្យមានរបបគ្រប់គ្រង និងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ដោយច្បាប់ដើម្បីបង្កើតឲ្យមានប្រព័ន្ធតម្លាភាពមួយដែលមានលក្ខណៈបើកចំហនិងប្រជាធិបតេយ្យ ។

នៅឆ្នាំ១៩៩៣រាជរដ្ឋាភិបាលបានបង្កើតច្បាប់ស្តីពី "**ប្រព័ន្ធហិរញ្ញវត្ថុ**" ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដើម្បីរៀបចំឲ្យមានថវិការដ្ឋមួយដែលជាតំពែង ចំណូល ចំណាយ របស់រដ្ឋ ។ ច្បាប់នេះក៏ដើម្បីធានាបាននូវការប្រមូលធនធានរបស់រដ្ឋបានល្អត្រឹមត្រូវគ្រប់ជ្រុងជ្រោយ ធានាបាននូវបន្ទុករបស់រដ្ឋឲ្យទៅតាមគោលដៅ និងធានាបាននូវពេលវេលាមួយជាក់លាក់ក្នុងការរៀបចំ និងអនុម័តថវិកាទៅតាមនីតិវិធីដែលច្បាប់បានកំណត់ ។

នៅក្នុងច្បាប់នេះបានអនុញ្ញាតដល់ រដ្ឋមន្ត្រីគ្រប់ក្រសួងនាយកគ្រប់ស្ថាប័នរដ្ឋបាលក្នុងការបង្កើតតំពែងចំណូល ចំណាយសំរាប់រដ្ឋអំណាចកណ្តាល និងរង្គភាពខាងក្រៅរបស់ខ្លួននៅតាមខេត្ត និងអង្គភាពក្រោមឱវាទ ហើយច្បាប់ហិរញ្ញវត្ថុនេះនឹងត្រូវបានអនុម័តដោយរដ្ឋសភាផងដែរ ។

---

[១] មុនមានការអនុវត្តប្រព័ន្ធវិមជ្ឈការក្នុងព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី ១ យន្តការកុងការរៀបចំថវិកា

### ១. ការរៀបចំ និងការអនុម័តថវិកា ( ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨ )

ស្ថិតក្រោមអំណាចនៃនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំគម្រោងដូចខាងក្រោម :

### ១.១ អំពីបរិបថ និងប្រតិទិនថវិកា

ឆ្នាំថវិកាចាប់ផ្តើមនៅ ថ្ងៃទី០១ ខែមករា ហើយនឹងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

នៅខែមីនារៀងរាល់ឆ្នាំរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំទស្សនៈវិស័យនៃថវិកាឆ្នាំបន្ទាប់ ដោយឆ្លងកាត់តាមការវិភាគនៃស្ថានការណ៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្មតិកម្មទាំងឡាយនៃការវិវត្តចំពោះស្ថានភាពក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម ព្រមទាំងការតៀបសង្កត់នៃម៉ាក្រូសេដ្ឋកិច្ចដែលអាចកើតមាន ។

នៅក្នុងក្របខ័ណ្ឌនេះ រដ្ឋាភិបាលកំណត់នូវអាទិភាពជាតិ និងការជ្រើសរើសដោយសមស្រប ។

រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្កើតលើមូលដ្ឋានទាំងនេះនូវចំនួនសរុបនៃគម្រោងថវិកាចែកចេញជា ចំណូល និងចំណាយ ព្រមទាំងរៀបចំសេចក្តីព្រាងដំបូងនៃថវិកា ដែលមានលក្ខណៈជារួមដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី ។

សេចក្តីព្រាងដំបូងនៃថវិកា ដែលបានអនុម័តពីរាជរដ្ឋាភិបាលក្រោមរូបភាពជាទិសដៅ ដែលកំណត់នូវលក្ខខណ្ឌទាំងឡាយក្នុងនោះត្រូវរៀបចំសំណើថវិកាសំរាប់ឆ្នាំបន្ទាប់ វិភាគទិន្នន័យសំខាន់ៗ

នៃស្ថានការណ៍សេដ្ឋកិច្ចជាទូទៅ និងផលវិបាកដែលអាចកើតមានដើម្បីធានានូវតុល្យភាពជាគោលសំខាន់ ព្រមទាំងការកំណត់ចំនួនថវិកាសរុបតាមក្រសួង ឬ អង្គការប្រហាក់ប្រហែល និងតាមប្រភេទនៃចំណាយទាំងឡាយ ។

ព្រមជាមួយគ្នារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំ និងផ្ញើជូនរដ្ឋអំណាចទាំងឡាយនូវសារាចរថវិកា ដែលមានលក្ខណៈបច្ចេកទេសដោយបញ្ជាក់ពីបែបបទនៃការបង្កើតគម្រោង ពីវិធីវាយតម្លៃ ដែលត្រូវអនុវត្តពីការបង្ហាញជូនសំរាប់ការអនុម័ត និងឯកសារយុត្តិការដែលត្រូវផ្តល់ជូន។

រដ្ឋមន្ត្រីគ្រប់ក្រសួង នាយកគ្រប់ស្ថាប័នរដ្ឋបាល បង្កើតគម្រោងចំណូល ចំណាយ ជាកំណត់របស់ខ្លួនសំរាប់រដ្ឋអំណាចថ្នាក់កណ្តាល សំរាប់អង្គភាពខាងក្រៅទាំងឡាយរបស់ខ្លួននៅតាមខេត្តនានា និងអង្គភាពក្រោមឱវាទ។ គម្រោងទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅខែកញ្ញា ។

នៅខែកញ្ញា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវប្រមូលផ្តុំគ្រប់សំណើចំណាយទាំងអស់ដើម្បីពិនិត្យ និងពិភាក្សាជាមួយរដ្ឋមន្ត្រីពាក់ព័ន្ធដើម្បីធ្វើការកែតម្រូវនូវអ្វីដែលចាំបាច់ ហើយស្របតាមបញ្ញត្តិនៃការណែនាំថវិកា និងបន្ថែមលើគម្រោងចំណូលនូវអ្វីដែលចាំបាច់ទាំងនោះ ។

នៅខែវិច្ឆិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកសាងនូវគម្រោងច្បាប់ហិរញ្ញវត្ថុដែលពិនិត្យ និងយល់ព្រមពីរាជរដ្ឋាភិបាលនៅខែធ្នូ ដើម្បីពិភាក្សា និងអនុម័តមុនថ្ងៃទី ២៥ ខែ ធ្នូ ។

## ១.២ ធនធាន និងបន្ទុករបស់រដ្ឋ

### ក. ធនធានរបស់រដ្ឋ

ធនធានអចិន្ត្រៃយ៍របស់រដ្ឋរួមមាន : ចំណូលប្រក្រតី និងចំណូលមូលធន ។ ចំណូលទាំងពីរនេះ ប្រមូលផ្តុំជាបីប្រភេទ :

ប្រភេទទី១ : ពន្ធដារ និងពន្ធអាករ ( ពន្ធលើផលទុនប្រាក់ចំណេញ លើប្រាក់ចំណូលមូលធន ពន្ធលើបេតិកភណ្ឌ ពន្ធផ្ទៃក្នុង ពន្ធលើទ្រព្យសម្បត្តិ និងសេវាកម្ម ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស និងចំណូលសារពើពន្ធផ្សេងទៀត ) ។

ប្រភេទទី២ : ចំណូលមិនមែនសារពើពន្ធ(ទាក់ទងផល់ផលទុននៃទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត) ។

ប្រភេទទី៣: ចំណូលជាមូលធន (ចំណូលផ្ទៃក្នុងជាមូលធន អំណោយក្រៅប្រទេស ធនធានដែលខ្ចីបានពីគេ) ។

ចំណូលត្រូវបានកត់ត្រាចូលទាំងស្រុង ដោយមិនត្រូវទូទាត់ជាមួយចំណាយឡើយ ។ ម្យ៉ាងទៀតចំពោះអាណាប័កត្រូវបានហាមក្នុងការបង្កើនទឹកប្រាក់នៃឥណទានដែលបានអនុម័តក្នុងថវិកាដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយឡើយ ។

### ខ. បន្ទុករបស់រដ្ឋ

បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមាន : ចំណាយប្រក្រតី និងចំណាយជាមូលធន ។ បន្ទុកនេះត្រូវចែកជា ប្រាំប្រភេទថវិកា ។

ចំណាយប្រក្រតី មានបួនប្រភេទដូចតទៅ :

- ប្រភេទទីមួយ : មធ្យោបាយសេវាកម្ម

- ប្រភេទទីពីរ : ការប្រាក់ដែលខ្ចីពីគេ

- ប្រភេទទីបី : អន្តរាគមន៍សាធារណៈ

- ប្រភេទទីបួន : ចំណាយផ្សេងៗ និងពុំបានគ្រោងគិតទុក

-ចំណាយជាមូលធននៃថវិកា (ជាប្រភេទទី៥) គឺសំរាប់បំពេញការប្រតិបត្តិកម្មវិធី ឬគំរោងការវិនិយោគបំពេញអន្តរាគមន៍ជាមូលធនរបស់រដ្ឋទៅក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈសហគ្រាសរដ្ឋ ឬបំពេញគោលនយោបាយនៃការចូលរួមប្រាស្រ័យ និងសំរាប់បំពេញការសងបំណុល ។

គម្រោងចំណាយជាប្រក្រតី និងគម្រោងចំណាយជាមូលធនត្រូវរៀបចំឡើងដោយក្រសួងទាំងឡាយ និងអង្គការប្រហាក់ប្រហែលដោយគិតបញ្ចូលទាំងអង្គភាពរបស់ខ្លួនរដ្ឋបាលកណ្តាលអង្គភាពខាងក្រៅ និងគ្រប់សកម្មភាពរបស់ខ្លួន ។ ការវាយតម្លៃទៅលើសេចក្តីត្រូវការ ទាំងឡាយបានបង្កើតឡើងដោយផ្អែកទៅលើកម្មវិធី សកម្មភាព និងទៅលើទិសដៅនៃលទ្ធផលទទួលបានដោយកំណត់យ៉ាងច្បាស់លាស់ និងរក្សាទុករាល់ខ្ទង់ចំណាយដែលមាននៅក្នុងកម្មវិធី ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបង្កើតឡើងដោយទំនាក់ទៅនឹងក្រសួងពាក់ព័ន្ធនូវនិយាមឬឯកត្តាវង្វាស់វង្វាល់សំរាប់សកម្មភាពដ៏សំខាន់ៗ ក៏ដូចគ្នាដែរចំពោះសេវានិងផលប្រើប្រាស់ជាប្រចាំ ។ ការចំណាយជាមូលធនទាំងឡាយដែលទាក់ទងទៅនឹងកម្មវិធី ឬទាក់ទងដល់គម្រោងដោយឡែកដែលមានការយល់ព្រមពីមុនមក គឺសំដៅទៅលើគោលដៅដែលអាចទទួលបានយ៉ាងជាក់ស្តែងរាល់កម្មវិធី ឬគម្រោងគឺជាមុខ

សញ្ញានៃការវាយតម្លៃសំរាប់ចំណាយសរុបរបស់កម្មវិធីនៃគម្រោងនោះ ព្រមទាំងជាមុខសញ្ញាសំរាប់វាយតម្លៃរយៈពេលកំណត់ និងចង្វាក់នៃការទូទាត់សំរាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ ។

**១.៣ បទបញ្ញានៃថវិកា** ( ការទូទាត់ថវិកាអំឡុងពេលមិនទាន់មានច្បាប់ស្តីពី សវនកម្ម )

បទបញ្ញានៃថវិកាជាកម្មវត្ថុនៃច្បាប់មួយ ។ សេចក្តីព្រាងច្បាប់ទូទាត់ ពិនិត្យ កត់ត្រា នូវចំនួនទឹកប្រាក់ជាស្ថាពរ នៃការបង់ចូលចំណូល និងអាណាប័ណ្ណចំណាយ ដែលបានធ្វើក្នុងអំឡុងការគ្រប់គ្រង ។ សេចក្តីព្រាងច្បាប់នេះបដិសេធចោលឥណទានដែលមិនបានប្រើប្រាស់ ហើយលើកឡើងឲ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំដែលត្រូវដាក់បញ្ចូលក្នុង "គណនីរតនាគារ" ក្រោយការដកចេញនូវចំនួនទឹកប្រាក់ដែលនៅសល់ទំនេរលើធនធានជាយថាហេតុសំរាប់ការចាត់ចែងពិសេស ។

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវបានតាក់តែងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើមូលដ្ឋាននៃគណនីពិសេសទាំងឡាយដែលអ្នកបញ្ជាចំណាយ ត្រូវបង្ហាញនូវកិច្ចប្រតិបត្តិការចំណាយរបស់ខ្លួន និងគណនីគ្រប់គ្រងនៃគណនេយ្យសាធារណៈដែលត្រូវដាក់ឲ្យនៅក្រោមការត្រួតពិនិត្យរបស់ក្រុមពិនិត្យគណនីជាមុន។

ក្រុមពិនិត្យគណនី ជាស្ថាប័នជាន់ខ្ពស់នៃការត្រួតពិនិត្យហិរញ្ញវត្ថុ ។ ក្រុមនេះពិនិត្យគណនីទាំងឡាយ និងការគ្រប់គ្រងសេដ្ឋកិច្ចរបស់សហគ្រាសសាធារណៈ។ ក្រុមនេះវាយតំលៃលើ

លទ្ធផលជំនួយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរដ្ឋយល់ព្រមផ្តល់ឲ្យដល់ផ្នែកឯកជន ។

សមត្ថកិច្ចរចនាសម្ព័ន្ធ និងនីតិក្រមនៃអន្តរាគមន៍របស់ក្រុមត្រួតពិនិត្យគណនីត្រូវបានកំណត់ដោយច្បាប់ ។

ប្រតិបត្តិការដែលបង្ហាញដោយសេចក្តីព្រាងនៃច្បាប់ទូទាត់ត្រូវបានលាតត្រដាងក្នុងតារាងទាំងឡាយដែលបង្ហាញ ៖

១.ចំពោះចំណាយនៃថវិកាទូទៅ ៖ ការគ្រោងទុកដើមដំបូងនៃការអនុញ្ញាតថ្មី និងបញ្ជាចំណាយ ដោយបែងចែកទៅតាមក្រសួង ឬតាមអង្គការថ្នាក់ប្រហាក់ប្រហែលតាមប្រភេទ និងតាមជំពូក។

២. ចំពោះចំណូល ៖ ការគ្រោងទុកដើមដំបូង ព្រមទាំងការកែប្រែ និងការប្រមូល ដោយញែកតាម ប្រភេទ ជំពូក និងតាមប្រការ ។

៣. ការប្រៀបធៀបទឹកប្រាក់សរុប ៖ សំរាប់ការគ្រោងទុកចំណូល និងចំណាយ ព្រមទាំងការកែប្រែដែលបានធ្វើប្រសិនបើមានជាមួយនឹងសមិទ្ធកម្មសំរាប់ថវិការបស់រដ្ឋបាលសាធារណៈនីមួយៗ ។

**ផ្នែកទី ២ . ប្រវត្តនៃការបង្កើតថវិកាថ្នាក់ក្រោមជាតិ**

ក្នុងអំឡុងពេលជាង១០ឆ្នាំ (១៩៧៩-១៩៩១) ប្រទេសកម្ពុជាមានរចនាសម្ព័ន្ធគ្រប់គ្រងប្រទេសមួយដែលឈរលើទ្រឹស្តីសង្គមនិយម និងដែលបានកំណត់នូវលក្ខណៈប្រមូលផ្តុំនិយម (Centralisation)។ របបនេះបានចាប់កំណើតពីចុងអាវុធដោយបាន

ផ្លូវលំរបបព្រៃផ្សៃ អមនុស្សធម៌ គឺ របបកម្ពុជាប្រជាធិបតេយ្យ ។ ផ្តើមចេញពីការគ្រប់គ្រងបែបប្រមូលផ្តុំអំណាចនៅថ្នាក់មជ្ឈិមទើប រាជរដ្ឋាភិបាលអណ្តត្តិទី២បានសំរេចគ្រប់គ្រងថ្នាក់ឃុំ សង្កាត់ តាមប្រព័ន្ធវិមជ្ឈការ ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៤៦ថ្មី ក៏បានចែងថា " ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និង សង្កាត់" ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀប ចំអង្គការមួយ ។ ម៉្យាងទៀតលិទ្ធិប្រជាធិបតេយ្យទាមទារឲ្យមាន តម្លាភាព និងបើកចំហរដោយអនុញ្ញាតឲ្យមានការចូលរួមពីប្រជា ពលរដ្ឋគ្រប់ជាន់ថ្នាក់ជាពិសេសការអនុញ្ញាតឲ្យប្រជាពលរដ្ឋជា អ្នកត្រួតពិនិត្យកិច្ចការរដ្ឋ ពិសេស ចំណូល ចំណាយថវិការដ្ឋ ។ ការអនុវត្តបែបនេះរាជរដ្ឋាភិបាលយល់ថា " ដើម្បីឆាយជំរុញកិច្ច អភិវឌ្ឍន៍ឿនសេដ្ឋកិច្ច និងសង្គមរបស់យើងដែលបានខ្ទេចខ្ទាំ ដោយសារសង្រ្គាមម៉្យាងទៀត ឃុំ សង្កាត់ ក៏ជាអ្នកនៅជិតនឹង ប្រជាពលរដ្ឋផងដែរ "។

## ២. ដំណាក់កាលនៃការចាប់ផ្តើមអនុវត្តថវិកាថ្នាក់ក្រោមជាតិ

មកដល់ឆ្នាំ ១៩៩៦ រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តនូវ ប្រព័ន្ធវិមជ្ឈការ ។

នៅក្នុងច្បាប់ស្តីពី" ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៦ " រាជរដ្ឋាភិបាល បានកំណត់ជាបណ្តោះអាសន្ននូវមាត្រា ១២ ដល់ មាត្រា ១៨ ដោយតំរូវឲ្យខេត្ត ក្រុង មានថវិកាដាច់ដោយឡែក។ ហើយរាជរដ្ឋាភិបាល បានចេញជាអនុក្រឹត្យលេខ០៧ អនក្រ.បក

ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៦ស្តីពី "ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង" ដូចមានចែងក្នុងមាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨ ។ តែដោយអនុក្រឹត្យលេខ០៧អនក្រ.បកនេះគាក់តែងពុំសូវបានល្អទើប រាជរដ្ឋាភិបាល ក៏បានកែប្រែអត្ថបទអនុក្រឹត្យនេះទៅជាច្បាប់តែម្តងដើម្បីឲ្យមានលក្ខណៈបច្ចេកទេសពេញលេញដែលហៅថា ច្បាប់ស្តីពី "របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង" ។ ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើនាថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៨ តាមរយៈព្រះរាជក្រមលេខ ជស/រកម/០៣ ។

ចាប់ពីពេលនោះមក ប្រព័ន្ធថវិការដ្ឋចាប់ផ្តើមបែងចែកជាពីរថ្នាក់គឺ ថ្នាក់ជាតិ និង ថ្នាក់ខេត្ត ក្រុង ។ ក្នុងច្បាប់នេះបានកំណត់ថា : នៅក្នុងវិស័យហិរញ្ញវត្ថុ អភិបាលខេត្ត ក្រុង ជាអ្នកទទួលអនុវត្តបន្តនូវអំណាចរបស់រដ្ឋ និងស្ថិតនៅក្រោមរដ្ឋមន្ត្រីដែលជាសមត្ថកិច្ច ។

អភិបាលខេត្ត ក្រុងជាអ្នករៀបចំថវិការបស់ ខេត្ត ក្រុង។ របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ត្រូវស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ខេត្ត ក្រុង ទទួលបន្ទុកគ្រប់គ្រងកិច្ចការក្នុងមណ្ឌលដែនដីរបស់ខ្លួនដើម្បីធានាឲ្យសេវាសាធារណៈ ដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់រដ្ឋ ឆ្លើយតបនឹងតំរូវការរបស់ប្រជាពលរដ្ឋក្នុងខេត្ត ក្រុង របស់ខ្លួន។

ថវិកាខេត្ត ក្រុង ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ០១ នស.៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ។

## ២.១ ថវិកាខេត្ត ក្រុង

### ២.១.១ ការរៀបចំ និងអនុម័តថវិកាខេត្ត ក្រុង

ការរៀបចំថវិកាខេត្ត ក្រុង ត្រូវបានអនុវត្តតាមច្បាប់ស្តីពី " របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង " ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០២៩៨/០៣ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ។

យោងមាត្រា១៨ នៃច្បាប់នេះចែងថា : គំរោងថវិកាខេត្ត ក្រុងត្រូវរៀបចំឡើងដោយអភិបាលខេត្ត ក្រុង ទៅតាមនីតិវិធីដែលបានកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ គំរោងថវិកាខេត្ត ក្រុង ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ០១ ខែកញ្ញានៃឆ្នាំនីមួយៗ ។ម្យ៉ាងទៀត ចំពោះគំរោងនេះក៏ត្រូវបញ្ជូនមក រដ្ឋសភាពិនិត្យ អនុម័តយល់ព្រមផងដែរ ។ ការបែងចែកកញ្ចប់ថវិកានេះទៅតាមខេត្ត ក្រុង នីមួយៗត្រូវធ្វើឡើងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

### ២.១.២ បន្ទុក និងធនធានរបស់ខេត្ត ក្រុង

**ក. ចំណាយរបស់ខេត្ត ក្រុង :**

១- ជួសជុលថែទាំទីស្នាក់ការខេត្ត ក្រុង ឬការជួលផ្ទះ ឬបន្ទប់ប្រសិនបើមាន។

២- សោហ៊ុយចំណាយថែរក្សាលិខិត និងឯកសារទាំងឡាយដែលជាបន្ទុករបស់ខេត្ត ក្រុង ។

៣- ចំណាយបៀវត្សរ៍ និងប្រាក់បំណាច់របស់បុគ្គលិកដែល

៤- សោហ៊ុយចំណាយដំណើរការរបស់សេវារដ្ឋបាលដែលស្ថិតនៅក្រោមសមត្ថកិច្ចខេត្ត ក្រុងព្រមទាំងសេវាសាធារណៈមានជាអាទិ៍ដូចជា : ការបំភ្លឺសាធារណៈ ការប្រឆាំងនឹងអគ្គីភ័យ ការប្រមូលសំរាម និងអន្តរាគមន៍ក្នុងវិស័យជំនួយសង្គមកិច្ច អនាម័យសុខាភិបាល ។

៥- ចំណាយសំរាប់ការរៀបចំ ការថែទាំ និងការជួសជុលធំនូវសំណង់អាគារសាធារណៈ បរិក្ខាសម្ភារភាពគ្រប់ប្រភេទដែលរដ្ឋប្រគល់ឲ្យខេត្ត ក្រុងកាន់កាប់មានជាអាទិ៍ដូចជាៈ អគាររដ្ឋបាល អគារសិក្សា មន្ទីរពេទ្យ ទីផ្សារសាធារណៈ បរិក្ខាកីឡា និងវប្បធម៌។

៦-សោហ៊ុយចំណាយថែទាំផ្លូវថ្នល់ សួនច្បារសាធារណៈ និងចំណាយសំរាប់ការរៀបជាជួរ ។

៧-សោហ៊ុយចំណាយសំរាប់ថែទាំប្រឡាយលូ អណ្តូងទឹក ក្បាលម៉ាស៊ីនទឹក ប្រឡាយបង្ហូរទឹកមិនស្អាត ឬទឹកភ្លៀង ។

៨-ចំណាយទាំងឡាយណាដែលស្ថិតក្នុងបន្ទុករបស់ខេត្ត ក្រុងដែលច្បាប់ ឬ បទបញ្ញាដែលបានកំណត់ ។

- ចំណាយបន្ទាប់បន្សំ : សោហ៊ុយទទួលភ្ញៀវ ការប្រជុំ

និងសំរាប់ដំណើរទស្សនកិច្ចផ្សេងៗ ។ ខ្ទង់ចំណាយទាំងនោះអាចគ្រោងបានតែនៅក្នុងករណីដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់ និងមិនធ្វើឲ្យបាត់តុល្យភាពថវិកា ។

ខ- ចំណូលរបស់ខេត្ត ក្រុង

មាត្រា១៧ នៃច្បាប់នេះចែងថា : ចំណូលថវិកាសំរាប់ការប្រព្រឹត្តទៅរបស់ខេត្ត ក្រុង ត្រូវបានផ្គត់ផ្គង់ដោយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។ ចំណូលនោះរួមមាន :

⇨ ចំណូលសារពើពន្ធ (ច្បាប់សារពើពន្ធ)

-ជំពូក១០-០៨ ពន្ធលើដីមិនប្រើប្រាស់

-ជំពូក១១-០១ ពន្ធប្រថាប់ត្រា

-ជំពូក១២-០៣ ពន្ធប៉ាតង់

-ជំពូក១២-០៥ ពន្ធសត្តឃាដ

-ជំពូក១២-០៦ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ។

⇨ ចំណូលមិនមែនសារពើពន្ធ

-ជំពូក២០-០៣-១៣ ចំណូលពីការផ្គត់ផ្គង់អគ្គិសនីនៅតាមខេត្ត ក្រុង

-ជំពូក២០-០៣-១៤ ផលទុននៃរដ្ឋាករទឹកនៅតាមខេត្ត ក្រុង

-ជំពូក២០-០៥ ចំណូលពីការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ ( ផ្សារ ចំណតរថយន្ត កំពង់ផ កន្លែងលក់ដេញថ្លៃ)

-ជំពូក២១-០៥ ចំណូលផ្សេងទៀតរបស់ខេត្តក្រុង ។

# បន្ទុក និងធនធានរបស់ខេត្ត ក្រុង

## ១- ចំណាយរបស់ខេត្ត ក្រុង

| ជួសជុលស្នាក់ការ | ថែរក្សាលិខិតឯកសារ | បៀវត្ស និង ប្រាក់បំណាច់ | ដំណើរការសេវាផ្ទាល់ | ថែទាំផ្លូវ និងស្ពាន | ប្រឡាយ លូ ទឹក អណ្តូង ក្បាលម៉ាស៊ីនទឹកការបញ្ចេញ ទឹកមិន ស្អាត រំដៀង | ចំណាយទាំងឡាយ ដែលច្បាប់ ឬបទបញ្ញា បានកំណត់ | ទទួលភ្ញៀវ ប្រជុំ និងទស្សនកិច្ច |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## ២- ចំណូលរបស់ខេត្ត ក្រុង

| ពន្ធ | | | | | ពុំមែនពន្ធ | | | |
|---|---|---|---|---|---|---|---|---|
| ជំពូក៧០ ០៤ ដីមិនប្រើប្រាស់ | ជំពូក៧១ ០១ ប្រដាប់ប្រា | ជំពូក៧៦ ០៣ ប៉ាតង់ | ជំពូក៧២ ០៥ សណ្ឋាគារ | ជំពូក៧២ ០៦ យានជំនិះ | ជំពូក៧០ ០៣_១៣ ផ្គត់ផ្គង់អគ្គិសនី | ជំពូក៧៣ ០៥ ផលទុនរោងការទឹក | ជំពូក៧៥ ០៥ កាន់កាប់ទ្រព្យរដ្ឋ ( ផ្សារ ចំណត កំពង់ផែ កន្លែងលក់ផ្សេងៗ ) | ផ្សេងៗ |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

បញ្ជាក់ ៖ ខេត្ត ក្រុង ក្នុងសិទ្ធិផ្ទៃក្នុង

### ៣ . ដំណើរច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នាឆ្នាំ ២០០១

នាថ្ងៃទី១២ ខែមករាឆ្នាំ២០០១ រដ្ឋសភាបានផ្តល់សច្ចាប័នលើសេចក្តីព្រាងច្បាប់ស្តីពី " ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ " និងព្រឹទ្ធសភាបានយល់ព្រមលើគតិច្បាប់ទាំងស្រុងនាថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០១ ច្បាប់នេះបានចូលជាធរមានតាមរយៈព្រះរាជក្រមលេខនស/រកម/០៣០១/០៥ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ។ ច្បាប់នេះបានអនុញ្ញាតដល់ ឃុំ សង្កាត់ តាមរយៈមាត្រាមួយចំនួនដូចខាងក្រោម :

- -មាត្រា៧៣ " ឃុំ សង្កាត់ មានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ " ។
- -មាត្រា៧៩ " ឃុំ សង្កាត់ ត្រូវរៀបចំអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ " ។
- -មាត្រា៧៤ " ឃុំ សង្កាត់ មានសិទ្ធិទទួលចំណូលផ្ទាល់ ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកំរៃសេវា"
- -មាត្រា៧៥ "ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន "
- -មាត្រា៧៦ " ឃុំ សង្កាត់ មានសិទ្ធិទទួលកំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់

ឲ្យអនុវត្ត "

-មាត្រា៧៧ " រដ្ឋបង្កើតឲ្យមានមូលនិធិឃុំ សង្កាត់ "

-មាត្រា៨៣ " របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ "

-មាត្រា៨២ " ឃុំ សង្កាត់ ត្រូវបង្កើតឲ្យមាននូវប្រព័ន្ធគ្រប់គ្រងតាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន :

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាពប្រសិទ្ធភាព និងមានការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រងការតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុ ឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ។

**៣.១ ថវិកា ឃុំ សង្កាត់**

៣.១.១ ការរៀបចំ និងអនុម័តថវិកា

របបហិរញ្ញវត្ថុឃុំ សង្កាត់ ត្រូវកំណត់តាមអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ ២០០២ ។

ការរៀបចំថវិកាឃុំ សង្កាត់មានប្រតិបត្តិការដូចខាងក្រោមៈ

- ថវិការបស់ឃុំ សង្កាត់ ចាប់ផ្តើមពីថ្ងៃទី ០១ ខែមករា និងបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ។

- មេឃុំ ចៅសង្កាត់ ទទួលខុសត្រូវរៀបចំគំរោងថវិកា ។

- ក្រុមប្រឹក្សាឃុំ សង្កាត់ អនុម័តគំរោងថវិកានាកិច្ចប្រជុំជាសាធារណៈឲ្យបានមុនថ្ងៃទី ៣១ ខែតុលា។

-មេឃុំ សង្កាត់ ត្រូវបញ្ជូនគំរោងថវិកាដែលអនុម័តរួចទៅអភិបាលខេត្ត ក្រុងឲ្យបានមុនថ្ងៃទី៥ ខែវិច្ឆិកាដើម្បីបញ្ជាក់ទទួលស្គាល់។ អភិបាលខេត្ត ក្រុង មិនមានសិទ្ធិកែប្រែ ឬ ជំទាស់ទៅនឹងជំរើសនៃការចំណាយដែលបានសំរេចដោយក្រុមប្រឹក្សានោះឡើយ ។ ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងបន្ទាន់ជាលាយល័ក្ខអក្សរដល់មេឃុំ ចៅ សង្កាត់ ឲ្យអនុវត្តវិធានការកែតម្រូវ ។ មេឃុំ ចៅសង្កាត់ត្រូវធ្វើការកែតម្រូវរយៈពេល ១៥ ថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹង។ ក្នុងករណីមេឃុំ ចៅសង្កាត់ខកខានមិនបានបញ្ជូនគម្រោងថវិកា ដែលត្រូវពិនិត្យឡើងវិញក្នុងរយៈពេលមួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹង នោះអភិបាលខេត្ត ក្រុង មានសិទ្ធិចាត់វិធានការកែសំរួលចាំបាច់ និងត្រូវជូនដំណឹងអំពីការសំរេច និងការកែសំរួលរបស់ខ្លួនដល់មេឃុំ ចៅ សង្កាត់ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹត្យនេះ ។ ប្រសិនបើមានភាពមិនចុះសំរុងគ្នារវាង មេឃុំ ចៅសង្កាត់ ជាមួយអភិបាលខេត្ត ក្រុង

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនករណីនេះទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីធ្វើការពិនិត្យ និងសម្រេចចុងក្រោយ ។

### ៣.១.២ ការអនុវត្តថវិកា

ថវិកាឃុំ សង្កាត់អាចនឹងត្រូវបានកែតម្រូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ ដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃចំណូល និងចំណាយ។

រតនាគារខេត្ត ក្រុង ត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់ និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម :

- ប្រមូល ឬទទួលចំណូលរបស់ឃុំ សង្កាត់
- ទូទាត់ចំណាយ ដែលបានចេញអាណត្តិដោយមេឃុំ ចៅសង្កាត់
- គ្រប់គ្រង និងបើកផ្តល់ថវិកាឃុំ សង្កាត់
- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុ តាមកាលកំណត់

### ៣.១.៣. ចំណូល ចំណាយរបស់ ឃុំ សង្កាត់

ចែកចេញជាពីរផ្នែក :

ផ្នែកទី ១ : ចំណាយចរន្ត និង ចំណូលចរន្ត

ផ្នែកទី ២ : ចំណាយមូលធន និងចំណូលមូលធន។

➢ ផ្នែកទី ១ :

ក. ចំណាយចរន្ត ចែកចេញជា ៧ ប្រភេទ :

ប្រភេទទី១ - ចំណាយបៀវត្ស និងប្រាក់បំណាច់

ប្រភេទទី២ - ចំណាយរដ្ឋបាលទូទៅ

ប្រភេទទី៣ - ចំណាយសេវាសាធារណៈ

ប្រភេទទី៤ - ចំណាយសំរាប់មុខងារជាភ្នាក់ងារ

ប្រភេទទី៥ - ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច

ប្រភេទទី៦ - ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច

ប្រភេទទី៧ - ចំណាយមិនបានគ្រោងទុក ។

ខ. ចំណូលចរន្ត : ចែកចេញជា ៥ ប្រភេទ :

ប្រភេទទី១ - ចំណូលពន្ធមូលដ្ឋាន

ប្រភេទទី២ - ចំណូលមិនមែនសារពើពន្ធ

ប្រភេទទី៣- ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់ សំរាប់រដ្ឋបាលទូទៅ

ប្រភេទទី៤ - ចំណូលពីការអនុវត្តន៍មុខងារជាភ្នាក់ងារ

ប្រភេទទី៥ - ចំណូលចរន្តផ្សេងៗ ។

## ➢ ផ្នែកទី ២

ក. ចំណាយមូលធន : ចែកចេញជា ២ ប្រភេទ :

ប្រភេទទី១- ចំណាយវិនិយោគផ្នែករដ្ឋបាល

ប្រភេទទី២- ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន។

ខ. ចំណូលមូលធន : ចែកចេញជា ៤ ប្រភេទ :

ប្រភេទទី១- ចំណូលមូលធនបម្រុងដូចមានចែងក្នុង មាត្រា ២២ នៃអនុក្រឹត្យនេះ

ប្រភេទទី២- ចំណូលពីការផ្ទេររបស់មូលនិធិឃុំ

សង្កាត់សំរាប់អភិវឌ្ឍន៍មូលដ្ឋាន

ប្រភេទទី៣- ចំណូល ពីការរួមចំណែករបស់ប្រជាពលរដ្ឋនៅមូលដ្ឋានទៅក្នុងតំលៃគម្រោង

ប្រភេទទី៤ - ចំណូលមូលធនផ្សេងៗ ។

គម្រោងថវិកាត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត។

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនគម្រោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្ត ក្រុង ឲ្យបានមុនថ្ងៃទី ៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់ ។

គម្រោងថវិកាត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម :

- របាយការណ៍សង្ខេបស្តីពី មូលដ្ឋានក្នុងការរៀបចំចំណូល និងចំណាយ ព្រមទាំងកំរិតនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា ។
- របាយការណ៍ស្តីពី ការអនុវត្តថវិកានៃឆ្នាំដំណើរការតារាងសង្ខេបនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ប្រសិនបើមាន ។
- កំណត់ហេតុស្តីពី កិច្ចប្រជុំអនុម័តលើគម្រោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និង បញ្ជាក់ការទទួលស្គាល់លើគម្រោងថវិកាឲ្យបានមុនថ្ងៃទី ៣០ ខែវិច្ឆិកា ។

ការត្រួតពិនិត្យអនុលោមភាព ត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោម :

១- ទំរង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំថវិកា ។

២- គុណភាពថវិកា និងការប្រើប្រាស់ចំណូលមូលធនដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ។

៣- លក្ខខណ្ឌនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ ដែលទទួលបាន ។

៤-ការគ្រោងឥណទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់ ។

៥- តំរូវការថវិកាវិនិយោគ សំរាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការរបស់ឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងមិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជម្រើសនៃការចំណាយ ដែលបានសម្រេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្រៅពីពិនិត្យលើលក្ខខណ្ឌទាំងឡាយ ដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព ។

# ជំពូក ២
## ដំណើរការរៀបចំថវិការដ្ឋ
### ( ពីឆ្នាំ ២០០៨ ដល់បច្ចុប្បន្ន )

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ នៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្នគឺអនុវត្តតាមច្បាប់ស្តីពី "ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨ /០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ។ វត្តមាននៃច្បាប់នេះបានធ្វើឲ្យច្បាប់ស្តីពី "ប្រព័ន្ធហិរញ្ញវត្ថុ" ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ និងច្បាប់ស្តីពី "របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្តក្រុង" ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ត្រូវបាននិរាករណ៍ ។

ច្បាប់នេះបានធ្វើការបែងចែកថវិការដ្ឋជាពីរថ្នាក់គឺ ៖

• **ថវិកាថ្នាក់ជាតិ** គឺជាថវិការបស់រដ្ឋបាលថ្នាក់ជាតិ

• **ថវិកាថ្នាក់ក្រោមជាតិ** គឺជាថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ ហើយថវិកានេះចែកជាបីថ្នាក់គឺ ថ្នាក់រាជធានី ខេត្ត ថ្នាក់ ក្រុង ស្រុក ខណ្ឌ និងថ្នាក់ ឃុំ សង្កាត់ ។

ច្បាប់ហិរញ្ញវត្ថុមានបីប្រភេទគឺ ច្បាប់ហិរញ្ញវត្ថុច្បាប់កែតំរូវ និងច្បាប់ទូទាត់ថវិកា ។ ច្បាប់ហិរញ្ញវត្ថុ គឺជាច្បាប់ដែលគ្រោងចំណូល និងចំណាយប្រចាំឆ្នាំរបស់រដ្ឋដែលត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្តមុខងារកេម្មវិធីការទទួលខុសត្រូវរបស់ក្រសួង

ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិស្តីពី វិស័យហិរញ្ញវត្ថុដែលច្បាប់កំណត់ ។ ច្បាប់កែតំរូវសំដៅដល់ច្បាប់កែតំរូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ច្បាប់ទូទាត់ថវិកា គឺដើម្បីត្រួតពិនិត្យ និងវាយតំលៃលទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ច្បាប់ហិរញ្ញវត្ថុទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រចាំឆ្នាំ ត្រូវអនុម័តដោយរដ្ឋសភា និងពិនិត្យដោយព្រឹទ្ធសភា ហើយនឹងត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រម ។ ការធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុត្រូវបានហាមឃាត់ ប្រសិនបើប៉ះពាល់ដល់តុល្យភាពគម្រោងថវិកាដែលបានស្នើឡើង។ ច្បាប់នេះត្រូវបោះពុម្ពផ្សាយឲ្យអនុវត្តជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំមិនត្រូវបានអនុម័តមុនថ្ងៃទី០១ខែមករានៃឆ្នាំការិយបរិច្ឆេទទេនោះ ថវិកាឆ្នាំមុន ត្រូវបានបន្តដោយស្របច្បាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម :

១-ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលគ្រប់ប្រភេទផ្សេងទៀតត្រូវបានអនុញ្ញាតនិងបន្តឲ្យប្រមូលក្នុងលក្ខខណ្ឌ និងតាមបែបបទដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និងក្នុងក្របខណ្ឌច្បាប់ព្រមទាំងបទបញ្ជាដែលមានជាធរមាន ។

២-ចំណាយចរន្ត ក្រៅពីបន្ទុកបំណុលសាធារណៈនៅតែបន្តអនុវត្តតាមក្របខ័ណ្ឌនៃថវិកាឆ្នាំមុនដោយគិតតាមវិធី១/១២

ជាបណ្តោះអាសន្នក្នុងខែនីមួយៗរហូតដល់ថវិកាថ្មីត្រូវបានអនុម័ត។

៣-ចំណាយមូលធននៃថវិកា ក្រៅពីវិលស់បំណុលសាធារណៈនៅតែបន្តអនុវត្តតាមក្របខណ្ឌ នៃថវិកាឆ្នាំមុនក្នុងក្របខណ្ឌឥណទានទូទាត់ដែលនៅទំនេរ ហើយពោចលើសពីនេះប្រសិនបើចាំបាច់ដោយមិនឲ្យការទូទាត់នោះលើសពី កំរិតឥណទានភ្ជាប់សន្យាដែលបានអនុម័តក្នុងថវិកាឆ្នាំមុន ។

៤- ចំណាយទាំងឡាយ ដែលជាកាតព្វកិច្ចទាក់ទងនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិ អន្តររដ្ឋាភិបាល និងកាតព្វកិច្ចទាក់ទងទៅនឹងបន្ទុកបំណុលសាធារណៈរួមមានៈការរំលោះប្រាក់ដើម ការបង់ការប្រាក់ កម្រៃសេវា និង/ឬ ការបង់ពិន័យជាយថាហេតុ ត្រូវបានរ៉ាប់រងជាបន្តមិនឲ្យដាច់តាមកិច្ចព្រមព្រៀងជាធរមាន ។

ថវិកាទូទៅរបស់រដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានត្រួតពិនិត្យដោយអង្គសវនកម្មជាតិ ដែលជាស្ថាប័នសាធារណៈ មានឯកពជ្យភាពសវនកម្ម និងធ្វើរបាយការណ៍សវនកម្មជូនទៅ រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដើម្បីជូនជ្រាបជាព័ត៌មាន ។

រដ្ឋបាលថ្នាក់ជាតិ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលដែលជាមន្ត្រីសាធារណៈ និងប្រតិបត្តិករនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូល ត្រូវប្រកាន់ខ្ជាប់នូវមូលដ្ឋានគោលការណ៍បូរណភាព សមាគតភាព សង្គតិភាព គណនេយ្យភាព តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយព្រមទាំងវិសាលភាពក្នុង

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល និងគោលការណ៍គន្លឹះទាំង ១១ យ៉ាងនៃថវិកា (យោងមាត្រា៥) ។

បច្ចុប្បន្នថវិការដ្ឋ ត្រូវបានរៀបចំដោយអនុលោមទៅតាមច្បាប់ស្តីពី " ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ " ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រម នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨ ។

## ផ្នែកទី ១ . អំពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ត្រូវបានចែកចេញជាពីរផ្នែក :

**ក- ផ្នែកទី១**

- សេចក្តីព្រាងច្បាប់ អនុញ្ញាតឲ្យប្រមូលគ្រប់ធនធានសាធារណៈ និងកំណត់ធនធានទាំងនោះជាទឹកប្រាក់ ។

- សេចក្តីព្រាងច្បាប់ បានកំណត់ទិសដៅ និងមធ្យោបាយអនុវត្តចំពោះចំណាយមូលធន ។

- សេចក្តីព្រាងច្បាប់ បានកំណត់នូវគណទានត្រូវផ្តល់ខ្ពស់បំផុតដែលជាគុណប្រយោជន៍ដល់ថវិការដ្ឋ និងគណនីពិសេសរបស់រតនាគារ ។

- សេចក្តីព្រាងច្បាប់រួមមាន បទបញ្ញត្តិទាំងឡាយដែលទាក់ទងដល់ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលមូលធន និងទាក់ទងដល់គ្រប់បញ្ញត្តិផ្សេងទៀត ។

ខ- ផ្នែកទី ២ (មានបង្ហាញក្នុងតារាង)

- តារាងបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនីដែលទាក់ទងដល់ចំណូលថវិការដ្ឋ ។

- សេចក្តីព្រាងច្បាប់ មានគម្រោងចំណាយចរន្តរបស់ថវិការដ្ឋ បែងចែកទៅតាម ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ហើយបែងចែកទៅតាមប្រភេទចំណាយដែលអនុម័ត ។

- សេចក្តីព្រាងច្បាប់ មានគម្រោងចំណាយមូលធនបែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល និងជាជំពូកដែលចែកចេញជា ឥណទានភ្ជាប់សន្យា និងឥណទានទូទាត់ ។

- សេចក្តីព្រាងច្បាប់ ត្រូវកំណត់បញ្ជីគណនីពិសេសរបស់រតនាគារជាតិដែលមានលក្ខណៈរដ្ឋបាល និងកំណត់គណនីពិសេសនីមួយៗនូវទឹកប្រាក់ចំណូល និងចំនួនទឹកប្រាក់ដែលត្រូវចំណាយ ។

### ៤. និយមន័យថវិការដ្ឋ

ជាតំរោងចំណូលចំណាយថវិកានៃរដ្ឋបាលថ្នាក់ជាតិដែលរៀបចំសំរាប់រយៈពេល១ឆ្នាំ ។ ថវិការដ្ឋបង្ហាញអំពី ប្រភពធនធាន និងទិសដៅបែងចែកប្រាក់របស់រាជរដ្ឋាភិបាល ។

ធាតុផ្សំនៃថវិការដ្ឋរួមមាន : **ថវិកាថ្នាក់ជាតិ** និង **ថវិកាថ្នាក់ក្រោមជាតិ** ។

## ៥. ថវិកាថ្នាក់ជាតិ

### ៥.១ កាលវិភាគនៃការរៀបចំថវិកា

ដំណើរការរៀបចំ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបាន អនុវត្តតាមដំណាក់កាលដូចខាងក្រោម :

**៚ ដំណាក់កាលទី១ :**

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (មីនា-ឧសភា)

នៅ សប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមដែលមានសង្គតិភាពទៅនឹងក្របខណ្ឌគោលនយោបាយជាតិ សម្រាប់ការអភិវឌ្ឍដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

នៅ សប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលកំណត់ដោយរាជរដ្ឋាភិបាល ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើសារាចរណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និងផែនការ

សកម្មភាពជាអាទិភាពរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបម្រើឲ្យគោលនយោបាយអាទិភាពរបស់វិស័យ និងគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ។ ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹម ថ្ងៃទី ១៥ ខែ ឧសភា ។

ចាប់ពីថ្ងៃទី ១៥ រហូតដល់ ថ្ងៃទី៣១ ខែឧសភា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការប្រមូលសរុបនូវផែនការយុទ្ធសាស្ត្រទាំងអស់របស់ក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានផ្ញើមក។

**៚ ដំណាក់កាលទី ២ :**

ការរៀបចំកញ្ចប់ថវិកា (មិថុនា-កញ្ញា)

នៅ សប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពី បច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកាព្រមទាំងធ្វើកំណត់បង្ហាញ និងឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ហើយផ្ញើជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំគម្រោងចំណូល ចំណាយ ថវិកាលម្អិតរបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោម

ជាតិត្រូវរៀបចំនូវគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្ដីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និងអាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គម្រោងថវិកាទាំងនេះត្រូវផ្ញើមក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុត **ត្រឹមថ្ងៃទី ១៥ ខែកក្កដា** ។

ចាប់ពីថ្ងៃទី ១៥ ដល់ ៣១ ខែកក្កដា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការប្រមូលផ្ដុំ បូកសរុបនូវគម្រោងចំណូល ចំណាយរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលខេត្ត និងរាជធានីដែលបានស្នើឡើង។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូលដើម្បីធ្វើតុល្យភាពថវិកាឡើងវិញរួចរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្ដីព្រាងច្បាប់នេះ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ។

➤ **ដំណាក់កាលទី ៣ :** ការអនុម័តថវិកា (តុលា-ធ្នូ)

នៅសប្ដាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ជូនសេចក្ដីព្រាងច្បាប់នេះដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ សម្រេច រួចដាក់ជូនរដ្ឋសភានៅ **សប្ដាហ៍ទីមួយនៃខែវិច្ឆិកា** ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភានៅសប្ដាហ៍ទីមួយនៃខែធ្នូ ដើម្បីឲ្យសេចក្ដីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុន **ថ្ងៃទី ២៥ ខែ ធ្នូ** ។

## តារាងសង្ខេបអំពីកាលវិភាគនៃការរៀបចំថវិកាថ្នាក់ជាតិ

| កាលបរិច្ឆេទ | ខ្លឹមសារ | សកម្មភាព |
|---|---|---|
| **ដំណាក់កាលទី១** (មីនា-ឧសភា) | - ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា | • សប្តាហ៍ទី១ ខែមីនា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ<br>• សប្តាហ៍ទី១ ខែមេសា<br>- ស.ហ.វ ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា<br>• ពីថ្ងៃទី ១៥-៣១ ខែឧសភា<br>-ប្តូកសរុបផែនការយុទ្ធសាស្ត្រថវិកា |
| **ដំណាក់កាលទី២** (មិថុនា-កញ្ញា) | - ការរៀបចំកញ្ចប់ថវិកា | • សប្តាហ៍ទី១ ខែ មិថុនា<br>- ស ហ វ ចេញសេចក្តីព្រាងសារាចរណែនាំស្តីពី បច្ចេកទេសនៃការរៀបចំគម្រោងថវិកា<br>• ថ្ងៃទី ១៥-៣១ ខែ កក្កដា<br>- ប្តូកសរុបគម្រោងថវិកា<br>• សប្តាហ៍ទី១-៤ ខែ សីហា<br>- ពិភាក្សាការពារគម្រោងថវិកា<br>• សប្តាហ៍ទី១-៤ ខែ កញ្ញា<br>- ប្តូកសរុបចំណូល ចំណាយរដ្ឋរួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ |
| **ដំណាក់កាលទី៣** (តុលា-ធ្នូ) | - ការអនុម័តថវិកា | • សប្តាហ៍ទី១ ខែ តុលា<br>- បញ្ជូនសេចក្តីព្រាងច្បាប់ជូន |

| | | |
|---|---|---|
| | | គណៈរដ្ឋមន្ត្រី<br>• សប្តាហ៍ទី១ នៃ វិច្ឆិកា<br><br>- ដាក់ជូនរដ្ឋសភាពិនិត្យ និងអនុម័ត<br>• ព្រឹទ្ធសភាពិនិត្យ និងអនុម័តឲ្យបាន មុនថ្ងៃ ២៥ ខែ ធ្នូ |

## ៥.២ ចំណូល ចំណាយថវិការដ្ឋ

### ៥.២.១ ចំណូលថវិការដ្ឋ

ជាធនធានអចិន្ត្រៃយ៍របស់រដ្ឋរួមមាន ចំណូលចរន្ត និង ចំណូលមូលធន។

ក- ចំណូលចរន្ត : ជាចំណូលប្រក្រតី ត្រូវបានបែងចែក ជា ២ ក្រុម និង ៣ ប្រភេទគឺ :

•ក្រុមទី ១ : ចំណូលពិត ( ជាចំណូលសាច់ប្រាក់ជាក់ស្តែង ដែលរួមមានចំណូលពន្ធ និង មិនមែនសារពើពន្ធ)។

- ប្រភេទទី១ : ចំណូលសារពើពន្ធគឺ ពន្ធក្នុងប្រទេស និង ពន្ធពាណិជ្ជកម្មក្រៅប្រទេស ។ ពន្ធក្នុងប្រទេស : ទទួលបានពីពន្ធដារ និងពន្ធគយក្នុងប្រទេស ។ ពន្ធពាណិជ្ជកម្មក្រៅប្រទេស : ទទួលបានពីការបង់ពន្ធ និងអាករលើការនាំចូល និងការនាំចេញ ។

- ប្រភេទទី២ : ចំណូលមិនមែនសារពើពន្ធ ( ផលទុននៃទ្រព្យរដ្ឋផលទុនលើការលក់ឬការជួលទ្រព្យរដ្ឋ និងសោហ៊ុយពីការពិន័យការឧបត្ថម្ភ ឬ អំណោយ ផលហិរញ្ញវត្ថុ និងផលពិសេស )។

• ក្រុមទី ២ : ចំណូលតាមដីកា ( ចំណូលមិនឆ្លងកាត់សាច់ប្រាក់ ) ។

- ប្រភេទទី៣ : ចំណូលតាមដីកា ( ចំណូលមិនឆ្លងកាត់សាច់ប្រាក់ ចំណូលនេះមានការងារនៃរដ្ឋទេយ្យ ( Excise ) ។

៧ចំណូលមូលធនៈ ប្រមូលផ្តុំគណនីទាំងឡាយដែលទាក់ទងនឹងមូលនិធិផ្ទាល់ ការខ្ចី និងបំណុលប្រហាក់ប្រហែល ។ ហើយចំណូលនេះបានបែងចែកជា ២ក្រុម និង ៣ ប្រភេទគឺៈ

•ក្រុមទី១ : ចំណូលពិត ( ជាចំណូលសាច់ប្រាក់ជាក់ស្តែងដែលមានដូចជា ចំណូលពីប្រភពផ្ទាល់ និងចំណូលពីប្រភពខាងក្រៅ ) ។

- ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់ ( ចំណូលទទួលបានពីក្នុងប្រទេស ) ។ ចំណូលនេះមានអចលកម្មហិរញ្ញវត្ថុ។ ចំណូលប្រភេទនេះរួមមានតំលៃដែលទទួលបានក្នុងក្របខណ្ឌ នៃការចល័តថវិកាដូចជា តំលៃដែលបានទទួលដោយការឲ្យខ្ចី (ភាគហ៊ុន ឬ មូលប័ត្រ) ។

- ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ (ចំណូលទទួលបានពីក្រៅប្រទេស) ។ ចំណូលនេះរួមមាន : ឧបត្ថម្ភធន វិនិយោគ ការខ្ចី និងបំណុលប្រហាក់ប្រហែល ។

• ក្រុមទី ២ : ចំណូលតាមដីកា (ចំណូលមិនឆ្លងកាត់សាច់ប្រាក់គឺជាកិច្ចប្រតិបត្តិការនៃការបង្វែរ ឬផ្ទេរធនធាន ) ។

- ប្រភេទ ទី៣ : ចំណូលតាមដីកា ( ដូចក្រុមទី ២ ) ។

សេចក្តីបញ្ជាក់ : ប្រភេទចំណូលនីមួយៗ ត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុអាច

លម្អិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ឧទាហរណ៍ :**

## ការគ្រប់គ្រងឆ្នាំ ២០១០

## តារាង «ក»

## ចំណូលថវិកាចរន្តរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ |
| ៧១ | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | ១.១២២.៤៨០,០ | ១.១១២,៣២០,០ |
| | ៧១០ | | ពន្ធនិងអាករពីការនាំចូល | ៩៩៩.៦០០,០ | ៩៩៩.៧០០,០ |
| | | ៧១០១ | | | |
| | | ៧១០២ | | | |
| | | ៧១០៣ | | | |
| | | ៧១០៤ | | | |
| | | ៧១០៥ | | | |
| | | ៧១០៦ | | | |
| | ៧១១ | | ពន្ធនិងអាករពីការនាំចេញ | ១២២.៨៨០,០ | ១១២.៦២០,០ |
| | | ៧១០៨ | | | |
| | | ៧១០៩ | | | |
| | | ៧១១០ | | | |
| | | ៧១១១ | | | |
| | | ៧១១២ | | | |

៥.២.២ ចំណាយថវិការដ្ឋ

ចំណាយថវិការដ្ឋមាន : ចំណាយចរន្ត និង ចំណាយមូលធន ។

៣ ចំណាយចរន្ត : ជាចំណាយជាប្រចាំដែលប្រមូលផ្តុំនូវគណនេយ្យទាំងឡាយសំរាប់កត់ត្រារាល់បន្ទុកតាមប្រភេទនីមួយៗ ក្នុងនោះមាន: ចំណាយពិត ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក។ ត្រូវ បានបែងចែកជា ២ ក្រុមនិង ៦ ប្រភេទគឺ :

• ក្រុមទី ១ : ចំណាយពិត (ជាចំណាយជាសាច់ប្រាក់ជាក់ស្តែងដែលរួមមាន : ចំណាយមធ្យោបាយ សេវា បន្ទុកហិរញ្ញវត្ថុ អន្តរាគមន៍សាធារណៈ ចំណាយផ្សេងៗ ការសង និងការបង្វិលវិញ) ។

- ប្រភេទទី ១: មធ្យោបាយ សេវា (ជាចំណាយដើម្បីទទួលនូវមធ្យោបាយ និងសេវាផ្សេងៗដែលរួមមាន : ការទិញសេវាខាងក្រៅផ្សេងៗ និងបន្ទុកបុគ្គលិក) ។

- ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ ( ជាចំណាយដែលទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ) ។

- ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ (ចំណាយសំរាប់ឧបត្ថម្ភធន និងជំនួយសង្គម ) ។

- ប្រភេទទី៤ : ចំណាយផ្សេងៗ (ចំណាយលើពន្ធនិងអាករ ការសង និងការបង្វិល ) ។

• ក្រុមទី ២ : ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក ។

-ប្រភេទទី៥ : ចំណាយតាមដីកា (ចំណាយមិនឆ្លងកាត់សាច់ប្រាក់ និងជាប្រតិបត្តិការនៃការបង្វែរ ឬ ផ្ទេរថវិកា )។

- ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក (ជាឥណទានដែលសភាបានអនុម័ត សំរាប់ចំណាយលើការងារចាំបាច់របស់រាជរដ្ឋាភិបាល) ។

បញ្ជាក់ៈ ប្រភេទចំណាយនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុអាចលម្អិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៧ ចំណាយមូលធន : គឺសម្រាប់ការអនុវត្តកម្មវិធីការអនុវត្តគម្រោងវិនិយោគ ការចូលរួមភាគកម្ម និងការទូទាត់បំណុល ។

ចំណាយមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

• ក្រុមទី ១ : ចំណាយពិត (ជាចំណាយសាច់ប្រាក់ជាក់ស្តែងរួមមាន ការទូទាត់ប្រាក់ខ្ចី បំណុលប្រហាក់ប្រហែល និងចំណាយលើអចលកម្ម ) ។

- ប្រភេទ ទី ១ : ការទូទាត់ប្រាក់កម្ចី និង បំណុលប្រហាក់ប្រហែល ( ការទូទាត់សងកម្ចី និងបំណុលហិរញ្ញវត្ថុប្រហាក់ប្រហែល ) ។

- ប្រភេទ ទី ២ : អចលកម្ម (ចំណាយលើអចលកម្មអរូបី រូបី ភាគកម្ម និងឥណទានពាក់ព័ន្ធ អចលកម្មហិរញ្ញវត្ថុផ្សេងៗ) ។

• ក្រុមទី ២ : ចំណាយតាមដីកា ( ចំណាយមិនឆ្លងកាត់

សាច់ប្រាក់ គឺជាការបង្វែរ ឬការផ្ទេរនូវសមិទ្ធិផលដែលអនុវត្តដោយដៃគូរអភិវឌ្ឍន៍) ។

- ប្រភេទ ទី៣ : ចំណាយតាមជីភា (ដូចក្រុមទី២ខាងលើ) ។

បញ្ជាក់ : ប្រភេទចំណាយនីមួយៗត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនីជាយថាហេតុ និងអាចលម្អិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឧទាហរណ៍ :

**ការគ្រប់គ្រងឆ្នាំ ២០១០**

**តារាង.ខ.**

**ចំណាយថវិកាជាតិរបស់រដ្ឋ**

| ក្រសួង.ស្ថាប័ន | ចំណាយចរន្ត | | | | | ចំណាយមូលធន | |
|---|---|---|---|---|---|---|---|
| | ប្រភេទទី ១ អត្ថប្រយោជន៍សោធន | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| សរុបរួមចំណាយ:<br>-រដ្ឋបាលកណ្តាល<br>-មន្ទីរជំនាញរាជធានី ខេត្ត | | | | | | | |
| ក-វិស័យរដ្ឋបាលទូទៅ:<br>-រដ្ឋបាលកណ្តាល<br>-មន្ទីរជំនាញរាជធានី ខេត្ត | | | | | | | |
| ខ-វិស័យការពារជាតិ | | | | | | | |
| -ក្រសួងការពារជាតិ<br>-មហាផ្ទៃ សន្តិសុខជាតិ | | | | | | | |
| គ-វិស័យសង្គមកិច្ច:<br>-រដ្ឋបាលកណ្តាល<br>-មន្ទីរជំនាញរាជធានី ខេត្ត | | | | | | | |
| ឃ-វិស័យសេដ្ឋកិច្ច:<br>-រដ្ឋបាលកណ្តាល<br>-មន្ទីរជំនាញរាជធានី ខេត្ត | | | | | | | |
| ង-ចំណាយមិនទាន់បែងចែក | | | | | | | |

*** មិនមានរៀបរាប់តាមជំពូក គណនី និងអនុគណនីទេ ព្រោះ ជាការ អនុវត្តជាក់ស្តែង។**

# តារាងសង្ខេបនៃថវិការដ្ឋបាលថ្នាក់ជាតិ (សរុបរួម)

| ឆ្នាំ | ចំណូល ([illegible]) | | | | | | ចំណាយ ([illegible]) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំណូលចរន្ត | | | ចំណូលមូលធន | | | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
| | [illegible] | | [illegible] | [illegible] | | [illegible] | ក្រុមទី១ [illegible] | | | | ក្រុមទី២ [illegible] | | ក្រុមទី[illegible] [illegible] | | ក្រុមទី[illegible] [illegible] |
| | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
| ១៩៩៣ | | | | | | | | | | | | | | | |
| ១៩៩៤ | | | | | | | | | | | | | | | |
| ១៩៩៥ | | | | | | | | | | | | | | | |
| ១៩៩៦ | | | | | | | | | | | | | | | |
| ១៩៩៧ | | | | | | | | | | | | | | | |

- [illegible] **ចំណូលចរន្ត និង ចំណូលមូលធន** ។
- [illegible]

- [illegible] **ចំណាយមូលធន** ។ [illegible] ។
- [illegible]
- [illegible] ។
- [illegible] ។

យោងតាមមាត្រា ២១,២២,២៣ នៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលមានព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ចែងថា · បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋ រួមមាន ចំណាយចរន្ត និង ចំណាយមូលធន ·

(បន្ទុកនេះបានចែកជាក្រុម និងប្រភេទ)

| ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|
| ក្រុម១ ៖ ចំណាយពិត | | | | ក្រុម២ ៖ ចំណាយតាមដីកា | | ក្រុម១ ៖ ចំណាយពិត | | ក្រុម២ ៖ ចំណាយតាមដីកា |
| ប្រភេទ១ មធ្យោបាយសេវា | ប្រភេទ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី៤ ចំណាយផ្សេងៗ | ប្រភេទទី៥ ចំណាយតាមដីកា | ប្រភេទទី៦ ចំណាយមិនបានគ្រោងទុក | ប្រភេទទី១ ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល | ប្រភេទទី២ អចលកម្ម | ប្រភេទទី៣ ចំណាយតាមដីកា |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

- ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជា ជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលំអិតជាងនេះទៀត ដោយប្រកាសរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
- ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស គឺជាឥណទានមានលក្ខណៈប៉ាន់ស្មាន ហើយពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពទៅប្រភេទចំណាយណាមួយផ្សេងទៀតឡើយ ។

យោងតាមមាត្រា១៣ នៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលមានព្រះរាជក្រមលេខ នស/រកម/០៩០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៨ ថែងថា · ធនធានអចិន្ត្រៃយ៍របស់រដ្ឋ រួមមាន ចំណូលចរន្ត និងចំណូលមូលធន·

| ចំណូលចរន្ត | | | ចំណូលមូលធន | | |
|---|---|---|---|---|---|
| ក្រុម១ ៖ ចំណូលពិត | | ក្រុម២ ៖ ចំណូលតាមដីកា | ក្រុម១ ៖ ចំណូលពិត | | ក្រុម២ ៖ ចំណូលតាមដីកា |
| ចំណូលសារពើពន្ធ | មិនមែនសារពើពន្ធ | | ពីប្រភពផ្ទាល់ | ពីប្រភពខាងក្រៅ | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

· ចំណុចនីមួយៗ [illegible]

## ផ្នែកទី ២

### ៦. ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។

### ៦.១ ប្រព័ន្ធហិរញ្ញវត្ថុ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិមានប្រពន្ធ័ហិរញ្ញវត្ថុ និងថវិកាចំនួនបីថ្នាក់គឺ :

១- ថ្នាក់រាជធានី ខេត្ត

២- ថ្នាក់ក្រុង ស្រុក ខណ្ឌ

៣-ថ្នាក់ឃុំ សង្កាត់ ( អនុក្រឹត្យលេខ ២៦ អន ក្រ.បកចុះ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ និងមានរៀបរាប់នៅក្នុងទំព័រទី ១៥ ដល់ទំព័រទី ២១ នៃសៀវភៅថវិកានេះ ) ។

រដ្ឋបាលឃុំ សង្កាត់អាចប្រើច្បាប់ស្តីពី " ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/ ០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ បានដោយអនុលោមតាមមាត្រា៥២ នៃច្បាប់នេះ ។

### ៦.២ ការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជាជំពូកមួយនៃច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ហើយក៏ត្រូវសុំការពិនិត្យ និងអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភាផងដែរ ។

### ៦.៣ កាលបរិច្ឆេទនៃឆ្នាំថវិកា

កាលបរិច្ឆេទនៃឆ្នាំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ចាប់ផ្តើម

នៅថ្ងៃទី០១ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ខែធ្នូ ។

ប្រសិនបើគម្រោងថវិកាប្រចាំឆ្នាំរបស់ថ្នាក់ក្រោមជាតិមិនត្រូវបានអនុម័តមុនថ្ងៃទី០១ខែមករានៃឆ្នាំសំរាប់ការិយបរិច្ឆេទដែលត្រូវអនុម័តទេ នោះអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិប្រមូលចំណូលតាមលក្ខខណ្ឌដែលបានអនុម័ត និងធានាចំណាយប្រចាំខែក្នុងកម្រិត ១/១២ នៃឆ្នាំថវិកា ។

## ៦.៤ ការរៀបចំ និងការអនុម័តថវិកា

ផែនការយុទ្ធសាស្រ្តថវិកា និងគម្រោងថវិការបស់រដ្ឋបាលនិងថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយអភិបាលនៃគណៈអភិបាល និងអនុម័តដោយក្រុមប្រឹក្សាទៅតាមនីតិវិធី ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំទៅតាមប្រតិទិនដូចខាងក្រោម :

**- ដំណាក់កាលទី១ :** ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា
( ពីខែមីនា ដល់ខែឧសភា )

រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសេចក្តីណែនាំស្តីពី ការរៀបចំយុទ្ធសាស្រ្តថវិកាដល់គ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងអស់ដើម្បីជូនដំណឹងដល់ក្រុមប្រឹក្សានីមួយៗនូវកម្មវិធី និងគម្រោងថវិកាក្នុងវិស័យរបស់ខ្លួនដែលត្រូវអនុវត្តនៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

ក្នុងនាមក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ ផែនការយុទ្ធសាស្រ្តថវិការបស់

ខ្លួនដោយឈរលើមូលដ្ឋានផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យពិភាក្សា និងអនុម័តហើយត្រូវផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបូកសរុបផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែឧសភា ។

**- ដំណាក់កាលទី២ : ការរៀបចំកញ្ចប់ថវិកា**

**( ពីខែមិថុនា ដល់ខែកញ្ញា )**

នៅសប្តាហ៍ទី១នៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំសារាចរណែនាំស្តីពី បច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ពីទម្រង់បែបបទនីតិវិធីនៃការរៀបចំគម្រោងថវិកា និងឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ ហើយផ្ញើទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន ។

អភិបាលនៃគណៈអភិបាលនីមួយៗ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពី បច្ចេកទេសនៃការរៀបចំគម្រោងថវិកានិងអាទិភាពគោលនយោបាយនៃរដ្ឋបាលរបស់ខ្លួន ដោយដាក់បញ្ចូលនូវរាល់ប្រភពថវិកាទាំងអស់ដែលត្រូវអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងដោយអភិបាល នៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោម

ជាតិនីមួយៗ ។ ដោយមានជំនួយពីប្រធានហិរញ្ញវត្ថុ នៃក្រុមប្រឹក្សា និងមន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវគម្រោងថវិកានេះ ដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរួចហើយត្រូវពិនិត្យ និងរៀបចំឡើងវិញនូវគម្រោងថវិកានេះ ដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំជាសាធារណៈយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ ខែមិថុនា ។

ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មឲ្យអភិបាលនៃគណៈអភិបាលខេត្តទទួលខុសត្រូវ ក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិនានា នៃច្បាប់នេះ ព្រមទាំងបទបញ្ជា បែបបទ និងនីតិវិធីនានាដែលកំណត់ដោយថ្នាក់ជាតិ ។ អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការគាំទ្របច្ចេកទេសនេះ ។

អភិបាលនៃគណៈអភិបាលខេត្តត្រូវធានាថាមន្ត្រី នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុបគម្រោងថវិការបស់ខេត្ត គម្រោងថវិការបស់ក្រុង គម្រោងថវិការបស់ស្រុកក្នុងខេត្តរបស់ខ្លួនចូលក្នុងទម្រង់ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយភ្ជាប់មកជាមួយនូវគម្រោងថវិកា និងសេចក្តីអត្ថាធិប្បាយ

ពន្យល់របស់ ខេត្ត ក្រុង ស្រុក ហើយត្រូវផ្ញើគម្រោង និងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែកក្កដា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំនីមួយៗ ។

ក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យនីត្យានុកូលភាព និងបញ្ជាក់អនុលោមភាពលើថវិការបស់ រាជធានី ថវិការបស់ខេត្ត ថវិការបស់ក្រុង និងថវិការបស់ស្រុក។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មនូវការពិនិត្យនីត្យានុកូលភាពទៅដល់អង្គភាពជំនាញរបស់ខ្លួន ឬអាជ្ញាធរណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់ ។

ដំណើរការពិនិត្យនីត្យានុកូលភាព ត្រូវមានការចូលរួមពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង និងស្រុក ដែលតំណាងឲ្យក្រុមប្រឹក្សាជាម្ចាស់ថវិកា តំណាងក្រសួងមហាផ្ទៃ សមាសភាពដទៃទៀតដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្នុងដំណើរការពិនិត្យនីត្យានុកូលភាពនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរដែលបានទទួលប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់លើគោលការណ៍ នៃការពិនិត្យនីត្យានុកូលភាពដូចខាងក្រោម ៖

- គម្រោងថវិកាបានរៀបចំឡើងទៅតាមទម្រង់ចំណាត់ថ្នាក់ថវិកាបែបបទ និងនីតិវិធីដែលបានកំណត់ ។

- មានការចូលរួមពីប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំថវិកា។

- ការគ្រោងឥណទានទៅតាមគោលការណ៍ចំណាយចាំបាច់ ។

- គម្រោងថវិកា ត្រូវគ្រោងតាមលក្ខខណ្ឌដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពជាក់លាក់ ដែលបានកំណត់ទុកជាមុន ។

- ធានាឲ្យមានតុល្យភាពពិតប្រាកដរវាងចំណូល និងចំណាយថវិកា ។

- មានការពិភាក្សាអនុម័តគម្រោងថវិកាក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា។

ក្នុងករណីដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យឃើញថា គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនស្របទៅនឹងគោលការណ៍ពិនិត្យនីត្យានុកូលភាពដូចបានចែងខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាជ្ញាធរដែលបានទទួលប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសម្រេចកែសម្រួល និងជូនដំណឹងជាលាយល័ក្ខអក្សរទៅអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំកែសម្រួលឡើងវិញទៅតាមនីតិវិធីជាធរមាន ។

➤ **ដំណាក់កាលទី៣** : ការអនុម័តថវិកា (ពីខែតុលា ដល់ធ្នូ)

នៅសប្តាហ៍ទី១ នៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជូនគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី១ ខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទី១ នៃខែធ្នូ ដើម្បីសម្រេចសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែធ្នូ ។

## តារាងសង្ខេបអំពី
## កាលវិភាគនៃការរៀបចំថវិកាថ្នាក់ក្រោមជាតិ

| កាលបរិច្ឆេទ | ខ្លឹមសារ | សកម្មភាព |
|---|---|---|
| **ដំណាក់កាលទី១**<br>(មីនា-ឧសភា) | -ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញសេចក្តីណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រដល់ក្រុមប្រឹក្សានីមួយៗនូវកម្មវិធីគម្រោងថវិកាក្នុងវិស័យរបស់ខ្លួន។<br>- អភិបាលនៃគណៈអភិបាលថ្នាក់ក្រោមជាតិជាអ្នករៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន រួចដាក់ជូនក្រុមប្រឹក្សាអនុម័ត។ បន្ទាប់មកផ្ញើជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬកសរុប ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែ ឧសភា។ |

| | | |
|---|---|---|
| **ដំណាក់កាលទី២**<br>(មិថុនា-កញ្ញា) | -ការរៀបចំកញ្ចប់ថវិកា | • សប្តាហ៍ទី១ ខែ មិថុនា<br>- ស.ហ.វ ចេញសេចក្តីព្រាងសារាចរណែនាំស្តីពី បច្ចេកទេសនៃការរៀបចំគម្រោងថវិកាផ្ញើទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>- អភិបាលនៃគណៈអភិបាល នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំគម្រោងចំណូល ចំណាយផ្អែកតាមសារាចរ និងអាទិភាពនៃគោលនយោបាយរបស់ខ្លួន។<br>-ប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា និងមន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុជួយក្នុងកិច្ចការនេះ។<br>- គម្រោងថវិកានេះត្រូវផ្សព្វផ្សាយជាសាធារណៈដើម្បីប្រមូលយោបល់ពីប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធរួចដាក់ជូនក្រុមប្រឹក្សាអនុម័តយ៉ាងយឺតត្រឹមថ្ងៃទី៣០ ខែមិថុនា។ |
| **ដំណាក់កាលទី៣**<br>(តុលា-ធ្នូ) | - ការអនុម័តថវិកា | • សប្តាហ៍ទី១ ខែ តុលា<br>- គម្រោងថវិកាថ្នាក់ក្រោមជាតិជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ជូនគណៈរដ្ឋមន្ត្រីពិនិត្យអនុម័ត រួចដាក់ជូនរដ្ឋសភាពិនិត្យ និងអនុម័ត ។<br>• ព្រឹទ្ធសភាពិនិត្យ និងអនុម័តឲ្យបានមុនថ្ងៃ ២៥ ខែ ធ្នូ |

### ៦.៥ បន្ទុក និងធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៦.៥.១ ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ៖

- ចំណាយប្រតិបត្តិការរដ្ឋបាល

-ចំណាយក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច

-ចំណាយក្នុងការអនុវត្តមុខងារជាជម្រើស

-ចំណាយក្នុងការអនុវត្តតួនាទីភារកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត ។

៦.៥.២ ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ៖

-ចំណូលពីប្រភពនៅមូលដ្ឋាន

-ចំណូលពីថ្នាក់ជាតិ

-ចំណូលផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត។

## ជំពូក ៣
## នីតិវិធីក្នុងការសុំសច្ចាប័នពីសភា

### ៧. កាលវិភាគនៃការសុំសច្ចាប័ន

#### ៧.១ ថវិកាថ្នាក់ក្រោមជាតិ

សប្តាហ៍ទី១ ខែតុលា គម្រោងថវិកាថ្នាក់ក្រោមជាតិជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ជូនគណៈរដ្ឋមន្ត្រី ពិនិត្យ អនុម័តរួចដាក់ជូនរដ្ឋ

សភាពិនិត្យ និងអនុម័ត ។ ព្រឹទ្ធសភាពិនិត្យ និងអនុម័តឲ្យបានមុនថ្ងៃ ២៥ ខែ ធ្នូ។

**៧.២ ថវិកាថ្នាក់ជាតិ**

សប្តាហ៍ទី១ ខែតុលា សេចក្តីព្រាងច្បាប់ត្រូវបានបញ្ជូនមកជូនគណៈរដ្ឋមន្ត្រីពិនិត្យអនុម័ត ។ ហើយនៅសប្តាហ៍ទី១ ខែវិច្ឆិកា ដាក់ជូនរដ្ឋសភាពិនិត្យ និងអនុម័ត។ ព្រឹទ្ធសភាពិនិត្យ និងអនុម័តឲ្យបានមុនថ្ងៃ ២៥ ខែធ្នូ ។

**៧.៣ ឯកសារភ្ជាប់**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាត្រូវភ្ជាប់មកជាមួយនូវ :

១-របាយការណ៍វិភាគពីនិន្នាការ ការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និងការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពី ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបបិយវត្ថុជាសារវន្ត ពិសេសតុល្យភាពថវិកា។

២-របាយការណ៍ទាំងឡាយណាដែលទាក់ទងទៅនឹងនិន្នាការចំណាយចរន្ត ដោយធ្វើការវិភាគ និងបង្ហាញពីស្ថានភាពឥណទានពាក់ព័ន្ធនឹងការអនុម័តឆ្នាំមុនទៅនឹងតម្រូវការ និងវិធានការថ្មីដែលមានសារៈសំខាន់ចាំបាច់សម្រាប់ការគ្រប់គ្រងថ្មី។

៣- គម្រោងកម្មវិធី និងគម្រោង ចំណាយមូលធនដែលរំលេចនូវ ឥណទានវិនិយោគ ឥណទានភ្ជាប់សន្យា ឥណទានទូទាត់ សម្រាប់កម្មវិធី និងគម្រោងក្នុងឆ្នាំ ការគ្រោងបម្រុងឥណទានដែលមានប្រភេទដូចគ្នាចាំបាច់សម្រាប់បន្តកម្មវិធី និង

គម្រោងទាំងនេះការវិភាគកម្មវិធី និងគម្រោងថ្មី ព្រមទាំងតម្រូវការឥណទានសម្រាប់កម្មវិធី និងគម្រោងថ្មីទាំងនេះ ដោយកំណត់តាមប្រតិទិនប្រើប្រាស់ដែលបានគ្រោងទុក ។

៤- ឯកសារពាក់ព័ន្ធផ្សេងទៀតដែលចាំបាច់សម្រាប់ជាព័ត៌មាន និងសម្រាប់ការត្រួតពិនិត្យរបស់រដ្ឋសភា និង ព្រឹទ្ធសភា។

**៨. ការចូលជាធរមាននៃអត្ថបទច្បាប់ហិរញ្ញវត្ថុ**

យោងមាត្រា៩៣ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា "ច្បាប់ដែលរដ្ឋសភា និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួច ហើយនឹងត្រូវបានព្រះមហាក្សត្រឡាយព្រះហស្ថលេខាប្រកាសឲ្យប្រើ " ។

ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឲ្យប្រើ ។ ក្នុងករណីច្បាប់នេះបានចែងថា ជាការប្រញាប់ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្ថលេខាប្រកាសឲ្យប្រើត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឲ្យទាន់តាមពេលកំណត់ខាងលើ ។

ដើម្បីធានាការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាពត្រូវចេញ អនុក្រឹត្យសេចក្តីសម្រេចបទបញ្ជា និងសារាចរណែនាំដោយរាជរដ្ឋាភិបាលព្រមទាំងប្រកាស និងសារាចរណែនាំផ្សេងទៀតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# តារាងចំណូល ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| ចំណូល | | | | | | ចំណាយ | | | |
|---|---|---|---|---|---|---|---|---|---|
| ពីប្រភពមូលដ្ឋាន | | ពីថ្នាក់ជាតិ | | | | ប្រតិបត្តិការរដ្ឋបាល | ការអនុវត្តមុខងារជាកាតព្វកិច្ច | ការអនុវត្តមុខងារជំរើស | តួនាទី និងភារកិច្ចផ្សេងៗ |
| ពន្ធដារ | មិនមែនពន្ធ | ចំណូលចែករំលែក | មូលនិធិផ្ទេរថវិកាជាតិ | | ថ្លៃសេវានៃមុខងារជាភ្នាក់ងារ | | | | |
| | | | មានភ្ជាប់លក្ខខណ្ឌ | គ្មានភ្ជាប់លក្ខខណ្ឌ | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

- តាមមាត្រា៣១ នៃច្បាប់នេះ រដ្ឋបង្កើតឲ្យមានមូលនិធិក្រុង ស្រុក ដែលមានគណនីដោយឡែកនៅរតនាគារជាតិ ដើម្បីទទួលមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថវិកាជាតិនិងទទួលធនធានពីប្រភពផ្សេងទៀតសម្រាប់ជាប្រយោជន៍ដល់ថវិកាថ្នាក់រដ្ឋបាលក្រុងស្រុក។

# ជំពូក ៤

# ការអនុវត្តមុខងារសវនកម្ម

## ផ្នែកទី ១ - ការអនុវត្តសវនកម្មលើថវិកា

### ៩. គណនេយ្យ និងការត្រួតពិនិត្យថវិកា

ថវិកាទូទៅរបស់រដ្ឋត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរសវនកម្មជាតិ។ ដោយអនុលោមតាមមាត្រា ៧៩ នៃច្បាប់ស្ដីពី " ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ " ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ចែងថា " គ្រប់ខណ្ឌ និងកិច្ចដំណើរការនៃសវនកម្មផ្ទៃក្នុង ផ្ទៃក្រៅ ត្រូវអនុវត្តតាមច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា " ។

### ៩.១ ប្រភេទនៃសវនកម្ម

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើ :

១. សេចក្ដីថ្លែងការណ៍ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួងស្ថាប័នដែលជាមូលដ្ឋានសំរាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុសរុប របស់រាជរដ្ឋាភិបាលនៅដំណាច់ឆ្នាំ នៃការិយបរិច្ឆេទដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមុនពេលដាក់ជូនអង្គការនីតិបញ្ញត្តិ ។

២. លើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងទៀតដែលសំណូមពរដោយភ្នាក់ងារផ្ដល់ជំនួយអន្តរជាតិ និងបណ្ដាឥណទាយកនៅក្នុងគម្រោងផ្ដល់មូលនិធិក្រៅប្រទេស ។

៣. ការអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមានរបស់សហគ្រាសវិនិយោគឯកជន ដែលបានទទួលការលើកលែងពន្ធ និងសម្បទានពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើអាជីវកម្មធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សវនកម្មទាំងនេះសង្កត់ធ្ងន់លើការអនុវត្តទៅតាមកិច្ចព្រមព្រៀង និងបណ្តាលក្ខខណ្ឌនៃការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

៤. តាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភា ឬព្រឹទ្ធសភា ឬក្រសួងនានា ឬរាជរដ្ឋាភិបាលសំរាប់ធ្វើការត្រួតពិនិត្យ ពិសេសឡើងវិញលើវិស័យមួយផ្នែក ឬទាំងអស់នៃកិច្ចប្រតិបត្តិការរបស់ម្ចាស់សំណើ។ ការអនុវត្តនៃសវនកម្មដែលមានចែងក្នុងមាត្រានេះ គឺស្ថិតនៅលើឆន្ទានុសិទ្ធិរបស់អគ្គសវនករ ។

៥. មានប្រព័ន្ធត្រួតពិនិត្យនានា ដើម្បីរៀបចំនូវមតិលើភាពសមស្រប គ្រប់ជ្រុងជ្រោយក្នុងការចាត់ចែងប្រព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅ ដែលបង្កើតឡើងដោយស្ថាប័នគ្រប់គ្រងលើសកម្មភាព និងកិច្ចប្រតិបត្តិការទាំងឡាយ ។

៦. មុខងារ ឬកិច្ចការកំពុងអនុវត្តរវាងស្ថាប័នគ្រប់គ្រង និងស្ថាប័នគ្រប់គ្រង ដើម្បីធានាសកម្មភាពកិច្ចប្រតិបត្តិការដែលទាក់ទងដល់មុខងារ នៅក្នុងបណ្តាស្ថាប័នគ្រប់គ្រងឲ្យមានការគោរពច្បាប់ បទបញ្ជានិងគោលការណ៍ទាំងឡាយដែលកំពុងអនុវត្តសវនកម្មនេះ រាប់បញ្ចូលទាំងលទ្ធកម្មសាធារណៈបៀវត្សបុគ្គលិក កិច្ចសន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបេសកម្ម ។

៧. វាយតំលៃអំពី ការសន្សំសំចៃការផ្តល់ឲ្យនូវផលល្អ ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់រាជរដ្ឋាភិបាល។ សវនកម្មនេះរាប់បញ្ចូលទាំងការពិនិត្យពិចារណាឡើងវិញ នៃប្រតិបត្តិការរបស់បណ្តាស្ថាប័នសាធារណៈ ទោះជាស្ថាប័នហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុក៏ដោយ ។

ការធ្វើសវនកម្មលើប្រភេទទាំងនេះ ត្រូវធ្វើដោយអាជ្ញាធរសវនកម្មជាតិ ។

**៩.២ ការអនុវត្តមុខងារសវនកម្មជាតិ**

ដោយអនុលោមតាមមាត្រា១នៃច្បាប់ស្តីពី "សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា " ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០បានកំណត់ថា " អាជ្ញាធរសវនកម្មជាតិ មានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល និងអនុវត្តមុខងារសវនកម្ម ផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងបណ្តាសហគ្រាសសាធារណៈផងដែរ " ។

**៩.២.១ អ្វីទៅជាការអនុវត្តសវនកម្មផ្ទៃក្រៅ ?**

សវនកម្មផ្ទៃក្រៅ គឺជាការពិនិត្យពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីគណនេយ្យ ប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រងថវិកា ដើម្បីផ្តល់ការធានា ឬទំនុកចិត្តថា :

ក. បណ្តាសកម្មភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈសេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍ ។

ខ. បណ្តាសកម្មភាពទាំងនេះត្រូវបានអនុវត្តដោយអនុលោមតាមតាមគោលការណ៍គណនេយ្យទូទៅ។

គ. ការត្រួតពិនិត្យនីតិវិធី និងការអនុវត្តដោយអនុលោមតាមច្បាប់ បទបញ្ជា កិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រងកិច្ចសន្យាកម្មវិធី និងលក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលទាក់ទងដល់ចំណូលចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រាជរដ្ឋាភិបាល ។

៩.២.២ ប្រភេទនៃសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល

ក. សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

ខ.សវនកម្មលើការគ្រប់គ្រងកម្មវិធីគម្រោងឥណទានដែលបានមកពីមូលនិធិក្រៅប្រទេស ។

គ.សវនកម្មលើប្រព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅលើបណ្តាស្ថាប័ន ។

ឃ. សវនកម្មលើការវាយតំលៃ ការផ្តល់លទ្ធផលល្អ និងប្រសិទ្ធភាពក្នុងការអនុវត្ត ។

ង. សវនកម្មលើអង្គការដែលមិនរកប្រាក់ចំណេញ និងសវនកម្មលើសហគ្រាសវិនិយោគឯកជន ដូចមានចែងក្នុងមាត្រា ២ នៃច្បាប់នេះ។

ច.សវនកម្មតាមសំណើពិសេស ។

## ៩.៣ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល

អគ្គសវនកម្មជាតិ អាចធ្វើសវនកម្មច្រើនប្រភេទដូចមានចែងរៀបរាប់ក្នុងចំនុច ៩-២-២ ខាងលើ ។ តែយើងលើកយកតែការ

ធ្វើសវនកម្មនៃចំនុច " ក " នៃ ៩-២-២ ស្តីពី សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសរុប មកសិក្សាប៉ុណ្ណោះគឺ មានដូចខាងក្រោម ៖

៩.៣.១ អ្វីទៅជារបាយការណ៍ហិរញ្ញវត្ថុសរុប ?

- ជាសេចក្តីព្រាងច្បាប់ស្តីពី "ការទូទាត់ថវិការបស់រដ្ឋ" ។ ជាឯកសារហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- អគ្គសវនករ ធ្វើសវនកម្មតែលើឯកសារទូទាត់ថវិកាទូទៅរបស់រាជរដ្ឋាភិបាលតែប៉ុណ្ណោះ។ ហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មជូនទៅ រដ្ឋសភា ព្រឹទ្ធសភា និងជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ហើយរបាយការណ៍នេះត្រូវចាត់ទុកជាឯកសារសាធារណៈ ។

៩.៣.២ ការធ្វើសវនកម្មលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋ

ក. ការបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋទៅអាជ្ញាធរសវនកម្មជាតិ

រាជរដ្ឋាភិបាល ត្រូវបញ្ជូនឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗទៅអាជ្ញាធរសវនកម្មជាតិដើម្បីធ្វើសវនកម្ម។ ក្នុងពេលជាមួយគ្នានោះ រាជរដ្ឋាភិបាលក៏បញ្ជូនសេចក្តីព្រាងច្បាប់នេះទៅរដ្ឋសភា និងព្រឹទ្ធសភាដើម្បីពិនិត្យ និងអនុម័តផង ដែរ ។

សំរាប់រយៈពេល ០៩ ខែ បន្ទាប់ពីបំណាច់ឆ្នាំនៃការិយបរិច្ឆេទ បើរាជរដ្ឋាភិបាលមិនបានផ្តល់ឯកសារស្តីពី ការទូទាត់ថវិកាប្រចាំឆ្នាំមកអាជ្ញាធរសវនកម្មជាតិទេ អគ្គសវនករត្រូវធ្វើ

របាយការណ៍ជូន រដ្ឋសភា និងព្រឹទ្ធសភាស្តីពី ការខកខាននេះ។

ខ. ធាតុផ្សំក្នុងឯកសារហិរញ្ញវត្ថុសរុប

ធាតុដែលផ្សំចូលក្នុងឯកសារនេះ គឺបានមកពីការរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នសាធារណៈ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយកព័ត៌មានមកធ្វើជាមូលដ្ឋានសំរាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល នៅដំណាច់ឆ្នាំនៃការិយបរិច្ឆេទមុនពេលដាក់ជូនអង្គការនីតិប្បញ្ញត្តិ។

គ. ការធ្វើរបាយការណ៍សវនកម្ម

អាជ្ញាធរសវនកម្មជាតិ ត្រូវធ្វើរបាយការណ៍សវនកម្មបញ្ជាក់លើឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ នេះទៅរដ្ឋសភា និងព្រឹទ្ធសភា ។

របាយការណ៍សវនកម្មនេះ គឺជាការបញ្ជាក់អំពី ភាពប្រក្រតី និងមិនប្រក្រតី ក្នុងកិច្ចបញ្ជីការគណនេយ្យ ការគ្រប់គ្រងថវិយវត្ថុ ទ្រព្យសកម្ម ដោយអង្គភាពនីមួយៗ និងត្រូវរាយការណ៍ជាប្រចាំជូន រដ្ឋសភា ព្រឹទ្ធសភានូវបញ្ហាទាំងឡាយណាដែលកើតចេញពីការបំពេញភារកិច្ច ឬប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដូចមានចែងក្នុងច្បាប់ ។ អំពីភាពមិនប្រក្រតីនេះក៏ត្រូវរាយការណ៍ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រសួងពាក់ព័ន្ធផងដែរ ។

ក្រោយពីមានការរៀបចំរបាយការណ៍ស្តីពី សវនកម្មនៃកិច្ចប្រតិបត្តិការរបស់អង្គភាពណាមួយរួចហើយអគ្គសវនករត្រូវ

បញ្ជូនច្បាប់ចំលងនៃរបាយការណ៍នេះទៅប្រធានស្ថាប័នគ្រប់គ្រង ។ ប្រសិនបើប្រធានស្ថាប័ននោះបានជូនយោបល់ជាលាយលក្ខអក្សរទៅអត្តសវនករក្នុងអំឡុងពេល២៨ថ្ងៃហើយអត្តសវនករត្រូវពិចារណាលើយោបល់ទាំងនោះ មុនពេលរៀបចំរបាយការណ៍ចុងក្រោយ។ផ្ទុយទៅវិញបើប្រធានស្ថាប័ននោះមិនឆ្លើយតបតាមកាលកំណត់ខាងលើរបាយការណ៍នោះត្រូវចាត់ទុកជាបានការ ។

**ឃ. ការសំងាត់នៃព័ត៌មានក្នុងរបាយការណ៍**

អត្តសវនករ មិនត្រូវបញ្ជូនព័ត៌មានពិស្តារនៅក្នុងរបាយការណ៍ដែលនឹងត្រូវផ្សព្វផ្សាយជាសាធារណៈទេប្រសិនបើ :

- អត្តសវនករយល់ថា ការលាតត្រដាងព័ត៌មាន គឺជាការផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ លើហេតុផលណាមួយដែលមានបញ្ជាក់នៅក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

- រាជរដ្ឋាភិបាល បានចេញលិខិតបញ្ជាក់មួយទៅអត្តសវនករថាការលាតត្រដាងព័ត៌មាននេះ គឺជាការផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ តាមហេតុផលណាមួយដែលមានបញ្ជាក់នៅក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

**☛ ព័ត៌មានដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ**

- ប៉ះពាល់ដល់សន្តិសុខ ការការពារជាតិ និងបូរណភាពទឹកដី ឬ ទំនាក់ទំនងអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

- ប៉ះពាល់ផលប្រយោជន៍ពាណិជ្ជកម្ម ស្របច្បាប់របស់បណ្តាអង្គភាព ឬបុគ្គល ។

☛ ការសម្រេចរបស់អគ្គសវនករ :

យោងតាមចំនុច " ឃ " ឬ មាត្រា ៣៧ ច្បាប់សវនកម្ម នៃព្រះរាជាណាចក្រកម្ពុជាអគ្គសវនករសំរេច :

ក. មិនរៀបចំរបាយការណ៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ

ខ. លុបចោលព័ត៌មានពិស្តារក្នុងរបាយការណ៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ ។

☛ ប៉ុន្តែចំពោះរបាយការណ៍បង្ហាញជូន រដ្ឋសភា ព្រឹទ្ធសភា ឬក្រសួងពាក់ព័ន្ធ អគ្គសវនករត្រូវរៀបចំបញ្ចូលព័ត៌មានពិស្តារ ដែលបានហាមឃាត់ដូចមានចែងក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

ង. សិទ្ធអំណាចលើការប្រមូលផ្តុំព័ត៌មាន

• **អគ្គសវនករអាចតំរូវឲ្យ :**

- ផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរ ហើយបញ្ជាក់ថា ត្រឹមត្រូវនៅចំពោះមុខច្បាប់ ។

- អគ្គសវនករ មានសិទ្ធិបញ្ជាក់រកការពិតនូវព័ត៌មាន និងរកភស្តុតាងជាក់លាក់ដែលបានផ្តល់ទាំងនោះ ។

☛ ត្រូវហាមឃាត់ចំពោះអ្នកផ្តល់ព័ត៌មាន នូវការក្លែងបន្លំរបាយការណ៍ទោះបីជា របាយការណ៍ផ្ទាល់មាត់ឬជាលាយល័ក្ខអក្សរក៏ដោយ ។

• **ទោសពិន័យ**

ជនណាក៏ដោយ ដោយពុំទាន់គិតដល់ការផ្តន្ទាទោសផ្សេងទៀតដែលប្រព្រឹត្តល្មើសនឹងច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១,០០០,០០០ លានរៀល ទៅ ៥,០០០,០០០

លានរៀល ឬ ដាក់ពន្ធនាគារពី ១ខែ ដល់ ៣ខែ ឬ ពិន័យជាប្រាក់ផង និងដាក់ពន្ធនាគារផង។ ហើយនឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ៥,០០០,០០០លានរៀលឡើងទៅ ឬ ដាក់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ ឬ ពិន័យជាប្រាក់ផង និងដាក់ពន្ធនាគារថែមទៀតផង ។

## ៩.៤ សវនកម្មផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល

### ៩.៤.១ គោលការណ៍ទូទៅ

យោងតាមមាត្រា ៧២ នៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ចែងថា :

- រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ និងអភិបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំក្របខណ្ឌ និងគ្រប់គ្រងប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាភាពត្រឹមត្រូវ ស្របតាមបទដ្ឋានបទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវណែនាំអំពី ការរៀបចំក្របខណ្ឌកិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលនឹងសហគ្រាសសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ៩.៤.២ គោលបំណងនៃការបង្កើតសវនកម្មផ្ទៃក្នុង

ដើម្បីជៀសវាងការធ្វើសវនកម្មស្ទួនគ្នា និងធ្វើសវនកម្មសារឡើងវិញ ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើការសំរបសំរួលការងារជាមួយអាជ្ញាធរសវនកម្មជាតិ។

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះ គឺជាដំណើរការរបស់រាជរដ្ឋាភិបាលដែលធ្វើឡើងដោយថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ដើម្បីផ្តល់នូវការធានាភាពសមស្របលើសមិទ្ធិកម្ម នៃកម្មវត្ថុតាមបណ្តាផ្នែក :

- ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ
- ភាពទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ
- ភាពសមស្របតាមបណ្តាច្បាប់ បទបញ្ជា គោលនយោបាយ នីតិវិធី និងការចាត់ចែងដែលត្រូវអនុវត្តន៍ ។

## ៩.៤.៣ ការបង្កើតសវនកម្មផ្ទៃក្នុង និងរចនាសម្ព័ន្ធ

- សវនកម្មផ្ទៃក្នុង ត្រូវបង្កើតឡើងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។ មានរចនាសម្ព័ន្ធស្មើនឹងនាយកដ្ឋានចំណុះផ្ទាល់ប្រធានស្ថាប័ន ហើយរាល់សហគ្រាសសាធារណៈត្រូវបង្កើតសវនកម្មផ្ទៃក្នុង ។
- ការរៀបចំការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងត្រូវកំណត់ដោយអនុក្រឹត្យ (អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃ ក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈលេខ៤០ អនក្រ.បកចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥)។ ដោយឡែកនៅមានក្រសួង ស្ថាប័ន មួយចំនួនពុំទាន់បានបង្កើត

សវនកម្មផ្ទៃក្នុងរួមមាន : ព្រឹទ្ធសភា (២០១៤-២០១៨) ព្រះបរមរាជវាំង និងក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិ [៣] ។

### ៩.៤.៤ តួនាទី និងភារកិច្ចសវនកម្មផ្ទៃក្នុង

តួនាទីសវនកម្មផ្ទៃក្នុង គឺត្រូវវាយតំលៃដោយឯករាជ្យនូវភាពសមស្រប គ្រប់គ្រាន់ នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាំងនោះ និងផ្តល់នូវការធានាលើភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យ ដែលកំពុងមាន និងកំពុងដំណើរការទៅតាមគោលបំណង ។

មានភារកិច្ច ធ្វើការវាយតំលៃដោយឯករាជ្យលើប្រសិទ្ធភាពក្នុងការអនុវត្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួនហើយត្រូវធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះទៅអាជ្ញាធរសវនកម្មជាតិ ។

### ៩.៤.៥ មុខងារ និងការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង

មុខងារនិងការទទួលខុសត្រូវរបស់សវនកម្មមានដូចខាងក្រោម :

១. ពិនិត្យឡើងវិញលើមុខងារ សកម្មភាពប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសមស្រប របស់ថ្នាក់ដឹកនាំក្នុងការអនុវត្តឲ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតំរង់ទិស

---

[៣] (ប្រសាសន៍ឯកឧត្តម អ៊ុក សារិវុធ អគ្គលេខាធិការនៃអាជ្ញាធរសវនកម្មជាតិបានលើកឡើងនាសិក្ខាសាលាស្តីពី "ការត្រួតពិនិត្យថវិកាដោយសភា" ។ នាថ្ងៃទី២៦-២៧ ខែតុលា ឆ្នាំ២០១០ នៅស្ថាប័នព្រឹទ្ធសភា)

ការចាត់ចែង និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព ។

២. កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព ។

៣. ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្រ្តដែលប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណវាស់វែងចំណាត់ថ្នាក់ និងរាយការណ៍អំពី ព័ត៌មានទាំងនោះ ។

៤. ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានទៅតាមគោលនយោបាយផែនការ នីតិវិធីច្បាប់ បទបញ្ជាទាំងឡាយ ដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍។ ក្នុងករណីក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈអនុវត្តពុំបានសម្រេច ដូចបានរៀបរាប់ខាងលើចាំបាច់សំណូមពរឲ្យមានការផ្លាស់ប្តូរ និងកែលំអ ។

៥.ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឲ្យបានត្រឹមត្រូវ ។

៦.វាយតំលៃភាពសន្សំសំចៃប្រសិទ្ធភាពលើការប្រើប្រាស់ធនធាន និងកំណត់ការកែលំអលើការអនុវត្តកិច្ចប្រតិបត្តិការព្រមទាំងការផ្តល់ជាអនុសាសន៍ ។

៧. ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយមូលធនលើលទ្ធផលការងារវិជ្ជមាន ឬអវិជ្ជមានតាមគោលបំណង គោលដៅ ដែលបានដាក់ចេញ និងតាមផែនការកំណត់។

៨. ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗ ដើម្បីធានាឲ្យមាន :

- តំរូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាស់លាស់
- ការត្រួតពិនិត្យផ្ទៃក្នុងសមស្រប ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រ ត្រូវបានប្រព្រឹត្តទៅក្នុងជំហានសមស្រប
- ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ ។

៩. ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតំលៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗ ក្រោយពេលតំឡើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផលមានសុវត្ថិភាព និងមានប្រសិទ្ធភាពខ្ពស់ ។

១០. ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តដើម្បីធានាថា វិធានការបានដាក់ចេញក្នុងគោលបំណងការពារការកេងបន្លំ។ ប្រសិនបើការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបានទាន់ពេលវេលា ។

១១. ពិនិត្យឡើងវិញលើការអនុវត្តតាមគោលការណ៍ណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលស្តីពី ឥរិយាបថ និងក្រមសីលធម៌ចំពោះមន្ត្រីរាជការ ។

១២. សំរបសំរួលការងារសវនកម្មផ្ទៃក្នុងជាមួយ អាជ្ញាធរសវនកម្មជាតិដើម្បីធានាទំហំការងារឲ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា ។

១៣.ធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួនហើយត្រូវធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះ ទៅអាជ្ញាធរសវនកម្មជាតិស្តីពី :

- សកម្មភាពកែលំអរតាមអនុសាសន៍សំខាន់ៗរបស់សវនកម្មផ្ទៃក្នុង ។

- សកម្មភាពសវនកម្មត្រូវបានផ្តោតលើហានិភ័យ និងបង្កើនភាព សន្សំសំចៃមានប្រសិទ្ធភាព និងផ្តល់លទ្ធផលល្អក្នុងកិច្ចប្រតិបត្តិការ ។

- សវនកម្មផ្ទៃក្នុង ត្រូវធ្វើការសម្របសម្រួលការងារជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីជៀសវាងការធ្វើសវនកម្មស្ទួនគ្នា និងធ្វើសវនកម្មសារឡើងវិញ ។

-ផែនការសវនកម្មផ្ទៃក្នុង ត្រូវមានភាពសមស្របច្បាស់លាស់គ្រប់គ្រាន់ ។

- ការរាំងលើព័ត៌មាន និងបញ្ជី ។

១៤.ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំត្រូវដាក់ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងសហគ្រាស សាធារណៈពិនិត្យ និងសម្រេច។

១៥. វាយតំលៃផែនការ ឬសកម្មភាព កែលំអរលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង។ ប្រសិនបើសកម្មភាពកែលំអនេះមិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្តដើម្បីឲ្យសម្រេច បានតាមសំណូមពរដែលអាចទទួលយកបាន ។

១៦. ផ្តល់លទ្ធភាពសមស្របគ្រប់គ្រាន់ ក្នុងការតាមដានសកម្មភាពកែលំអលើអនុសាសន៍ ។

១៧. ប្រធានសវនកម្មផ្ទៃក្នុង ត្រូវរាយការណ៍ដោយផ្ទាល់មាត់ជូនថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន ឬក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ ។

១៨. ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវនកម្មផ្ញើជូនដល់ផ្នែកនីមួយៗរបស់ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ដែលទទួលបន្ទុកកែលំអតាមអនុសាសន៍។ សវនកម្មផ្ទៃក្នុងត្រូវបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ។

១៩. អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗដែលប្រធានស្ថាប័ន ក្រសួង និងសហគ្រាស សាធារណៈប្រគល់ជូន ។

ប្រធានស្ថាប័ន ក្រសួងនីមួយៗ ត្រូវសម្របសម្រួលបែងចែកភារកិច្ចរវាងអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងនេះឲ្យសមស្រប ។

### ៩.៤.៦ បេសកកម្មសវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យអំពីកិច្ច

ប្រតិបត្តិការនៃការងារ និងវាយតំលៃសកម្មភាពរបស់អង្គភាព ដើម្បីជាជំនួយសំរាប់ថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និងក្រុមប្រឹក្សាភិបាលរបស់សហគ្រាស។ ការធ្វើសវនកម្ម គឺមានគោលដៅ :

១- ជួយដល់ផ្នែកនីមួយៗនៃក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈខាងលើ ដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួនឲ្យមានប្រសិទ្ធភាព ។

២- គោលដៅមួយទៀត គឺផ្តល់ឲ្យក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈនូវការវិភាគ ការវាយតំលៃអនុសាសន៍ មតិយោបល់ និងព័ត៌មានដែលទាក់ទងនឹងសកម្មភាពដែលបានត្រួតពិនិត្យ និងការពិនិត្យឡើងវិញ ។

**៩.៤.៧ ស្តង់ដារសវនកម្មផ្ទៃក្នុង និងក្រមសីលធម៌**

ដើម្បីធ្វើឲ្យមុខងារសវនកម្មផ្ទៃក្នុង អនុវត្តឲ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញផ្សាយការណែនាំលើ **ស្តង់ដារវិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង ក្រមសីលធម៌ ទំហំការងារ និងសិទ្ធិអំណាចនៃការគ្រប់គ្រង** ដែលត្រូវបានអនុវត្តដោយសវនកម្មផ្ទៃក្នុង ដោយពិគ្រោះយោបល់ជាមួយអាជ្ញាធរសវនកម្មជាតិ ។

**៩.៥ ការធ្វើសវនកម្មលើអាជ្ញាធរសវនកម្មជាតិ**

ក្នុងករណីចាំបាច់ និងតាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងនាមរដ្ឋសភា មានសិទ្ធិជ្រើសរើសសវនករពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរ

សវនកម្មជាតិ ។

ក្នុងករណីចាំបាច់យោង តាមសំណើរបស់គណកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា រដ្ឋសភាអាចសម្រេចបង្កើតគណៈកម្មការពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសម្មភាព និងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ (យោងច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១១០០/១១ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០០) ។

### ផ្នែកទី ២. ការត្រួតពិនិត្យថវិការដ្ឋដោយព្រះមហាក្សត្រ

យោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាមាត្រា ១៤០ ចែងថា " ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះត្រូវបានប្រកាសឲ្យប្រើ " ។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

- ច្បាប់ស្តីពី " ប្រព័ន្ធហិរញ្ញវត្ថុ " ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.សចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- ច្បាប់ស្តីពី " របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង" ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ១៩៩៨។

- ច្បាប់ស្តីពី " ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ " ។

- អនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពី " ប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់ " ។

- ច្បាប់ស្តីពី " ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ " ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០៨ ។

- ច្បាប់ស្តីពី "ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ"

- ច្បាប់ស្តីពី " សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា " ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ។

- អនុក្រឹត្យលេខ៤០ អនក្រ.បកស្តីពី " ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនីមួយៗ តាមបណ្តា ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ " ចុះថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ។













បោះពុម្ពផ្សាយដោយ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

វិមានចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ២១១ ៤៤១,២១១ ៤៤២, ២១១ ៤៤៣ ទូរសារ: (៨៥៥-២៣) ២១១ ៤៤៦
Email: oum_sarith@camnet.com.kh
Website: www.senate.gov.kh